# មេរៀនទី ៧ អំពើបាប និង សេចក្តីសង្គ្រោះ៖ បញ្ហា និង ដំណោះស្រាយ

"ប៊ិប! ថ្ងៃនេះ ពួកអ្នកធ្វើសំណង់ដែលកំពុងសង់ផ្ទះនៅក្បែរផ្ទះយើង ពួកគេកំពុងលាយបេតុង ដូច្នេះហើយ កុំទៅលេងជិតពួកគេណា ។ កូនឯងកំពុងពាក់អាវថ្មីផង"។

ប្រពន្ធរបស់ខ្ញុំចូលចិត្ត និយាយប្រាប់ខ្ញុំអំពីរឿងកាលដែលថាប្អូនប្រុសរបស់គាត់ ធុញនឹងការរំឭករបស់ម្តាយគាត់ខ្លាំងណាស់។ ក្រោយពីព្រមានមិនទាន់បានប៉ុន្មាន ប្អូនប្រុសរបស់ប្រពន្ធខ្ញុំ កាលដែលគេមានអាយុទើបតែប្រាំមួយឆ្នាំនោះ បានក្រោកឈរឡើង ហើយដើរចេញទៅយ៉ាងរឹងចចេស ឆ្ពោះទៅរកកន្លែងគេធ្វើសំណង់នោះ។ ពេលដែលគាត់ដើរទៅដល់ មានសត្វមេអំបៅមួយក្បាលបានទុំលើស្នូកសម្រាប់លាយបេតុងនោះ។ ប៊ិប បានអោនទៅរំដោះសត្វមេអំបៅដែលកំពុងជាប់គាំងនោះ ប៉ុន្តែគាត់បានបាត់បង់លំនឹងរបស់គាត់ ហើយក៏ធ្លាក់ចូលនៅក្នុងបេតុងនោះតែម្តងទៅ! បេតុងបានប្រឡាក់ចាប់តាំងពីក្បាល ហើយហូរដល់លើមុខរបស់គាត់។ អាវថ្មីរបស់គាត់បានប្រឡាក់អស់! ការចចេសរឹងរូសរបស់ប៊ិប ក៏បានផ្លាស់ប្តូរទៅជា ការឈឺចាប់ភ័យខ្លាចវិញ។ តើគាត់នឹងអាចប្រឈមមុខជាមួយនឹងម្តាយរបស់គាត់បានយ៉ាងដូចម្តេច? តើការមិនស្តាប់បង្គាប់របស់គាត់នឹង ផ្តល់ផលវិបាកអ្វីខ្លះ?

មនុស្សជាតិក៏ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះដែរ។ ស្នាព្រះហស្តដ៏ពេញដោយសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដែលជាប្រធានបទនៅក្នុងមេរៀនទី៦ ក៏ត្រូវបានសៅហ្មង និង ត្រូវបានពង្វក់ដោយអំពើបាប។ នៅក្នុងមេរៀននេះ យើងនឹងរៀននូវអ្វីដែលព្រះគម្ពីរបានថ្លែង អំពីដើមកំណើត និង ផលវិបាកនៃអំពើបាប។ អរព្រះគុណព្រះជាម្ចាស់ យើងមិនចាំបាច់ត្រូវបញ្ឈប់ការសិក្សារបស់យើងនៅក្នុងពេលដែលយើងអស់សង្ឃឹមឡើយ។ យើងក៏ត្រូវរៀនអំពីដំណោះស្រាយដែលព្រះគ្រិស្ត បានប្រទានឲ្យផងដែរ។ ចូរយើងទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ជួយយើងនៅក្នុងពេលដែលយើងសិក្សាអំពីប្រធានបទសំខាន់ៗទាំងនេះ។

## គម្រោងមេរៀន

ក. ធាតុពិតនៃអំពើបាប
ខ. ដើមកំណើតនៃអំពើបាប
គ. និស្ស័យរបស់អំពើបាប
ឃ. ផលវិបាកនៃអំពើបាប
ង. ការស្រោចស្រង់មនុស្សមានបាប

## វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. ប្រាប់ពីនិយមន័យ និង ភស្តុតាងនៃធាតុពិតរបស់អំពើបាប។
២. រៀបរាប់យ៉ាងត្រឹមត្រូវអំពីដើមកំណើតនៃអំពើបាប។
៣. ស្គាល់ពីទិដ្ឋភាពនៃអំពើបាប។
៤. រៀបរាប់អំពីផលវិបាកនៃអំពើបាប។
៥. បកស្រាយពីរបៀបដែលមនុស្សមានបាប ត្រូវបានស្រោចស្រង់ និង បកស្រាយពីលទ្ធផលនៃការស្រោចស្រង់។

## សកម្មភាពក្នុងការសិក្សា

១. ចូរអានគម្ពីរលោកុប្បត្តិ ២ - ៣ និង គម្ពីររ៉ូម ៥ - ៦ ដែលជាសេចក្ដីយោងសម្រាប់មេរៀននេះ ដែលមានទាក់ទងនឹងបញ្ហានៃអំពើបាប។ ចូរអានគម្ពីរអេសាយ ៥៣ ដើម្បីទទួលបានចំណេះដឹងអំពីដំណោះស្រាយដែលព្រះជាម្ចាស់បានប្រទានមកសម្រាប់អំពើបាប។ បន្ទាប់មក ចូរសិក្សាតាមដំណើររបស់មេរៀនដូចធម្មតា។
២. បន្ទាប់ពីអ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី៥ ដល់ទី ៧ (ជំពូកទី២) បន្ទាប់មក ធ្វើការប្រឡងសម្រាប់ជំពូកទីពីរ។

## ពាក្យសំខាន់ៗ

| | | |
|---|---|---|
| ការរំដោះបាប | ពិគ្រោះ | ទំនោរចិត្ត |
| ពុករលួយ | ការរសាយចិត្ត | ការបំពុល |
| ក្លែងបន្លំ | ដែលជាសត្រូវ | ភាពបះបោរ |
| ដែលឆបោក | គ្រាប់ | ការស្តារឡើងវិញ |

# ក. ធាតុពិតនៃអំពើបាប

**វត្ថុបំណងទី ១.** *ប្រាប់ពីនិយមន័យ និង ភស្តុតាងនៃធាតុពិតរបស់អំពើបាប។*

អំពើបាបអាចត្រូវបានគេឲ្យនិយមន័យថា ការមិនស្ដាប់បង្គាប់ និង ការបរាជ័យក្នុងការប្រតិបត្តិតាមច្បាប់ដែលព្រះជាម្ចាស់បានប្រទានមកដើម្បីដឹកនាំ សភាវៈដែលមានវិចារណញ្ញាណរបស់ទ្រង់។ ដោយច្បាប់របស់ព្រះជាម្ចាស់ គឺជាការសំដៅពីនិស្ស័យខាងឯសីលធម៌ របស់ទ្រង់ យើងត្រូវប្រតិបត្តិតាមច្បាប់នោះ ដើម្បីស្របទៅតាមនិស្ស័យដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ៗ មកកាន់យើងរាល់គ្នា អំពីធាតុពិតនៃអំពើបាប ក៏ដូចជាដើមកំណើត និស្ស័យ ផលវិបាក និង ការព្យាបាលឲ្យផុតពីបាបនោះផងដែរ។ ទដ្ឋិភាពនៃអំពើបាបទាំងអស់នេះ នឹងត្រូវបានលើកយកទៅវែងញែកស្របពេលដែលយើងសិក្សាមេរៀននេះទៅមុខ។

ដូចដែលយើងបានឃើញនៅក្នុងមេរៀនមុនរួចមកហើយថា មនុស្សគឺជាសភាវៈដែលមានវិចារណញ្ញាណ ។ ដូច្នេះហើយ ពួកគេក៏ដឹងថាពួកគេមានទោសបាបដែរ ប្រសិនបើពួកគេ ១) ធ្វើអ្វីដែលពួកគេមិនគួរនឹងធ្វើ ២) មិនធ្វើអ្វីដែលពួកគេគួរធ្វើ ៣) ធ្វើខ្លួនជាអ្វីដែលមិនមែនជាពួកគេ ឬ ៤) មិនព្រមធ្វើខ្លួនឲ្យសមជាអ្វីដែលជាពួកគេ ។ មានភស្តុតាងជាច្រើន អំពីធាតុពិតនៃអំពើបាប។ ភស្តុតាងទីមួយនៃភស្តុតាងទាំងនេះ គឺឃើញមាននៅក្នុងព្រះគម្ពីរ។

## ឃើញមានភស្តុតាងក្នុងព្រះគម្ពីរ

អំពើបាបគឺជាប្រធានបទធំមួយនៅក្នុងព្រះគម្ពីរ។ គម្ពីរលោកុប្បត្តិ ៣ មានកត់ត្រាទុកនូវ គ្រាដំបូងដែលមនុស្សធ្វើអំពើបាប។ ជំពូកទី៤ ក៏បន្តសាច់រឿងនេះ ដោយប្រាប់អំពីរបៀបដែលបញ្ហា បន្តប៉ះពាល់ទៅដល់កូនចៅនៃឪពុកម្ដាយដំបូងរបស់យើង។ នៅត្រង់ចំណុចនេះ ព្រះជាម្ចាស់បានមានព្រះបន្ទូលដ៏គួរឲ្យប៉ះពាល់ចិត្តមួយទៅកាន់លោកកាអ៊ីនថា៖ " បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកអោយធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ" (គម្ពីរលោកុប្បត្តិ ៤:៧)។ ប៉ុន្តែ លោកកាអ៊ីនបានចុះចាញ់អារម្មណ៍ច្រណែន ស្អប់ និង ចិត្តបះបោររបស់លោក ហើយក៏បានសម្លាប់ប្អូនប្រុសរបស់ខ្លួនទៅ។

## *លំហាត់អនុវត្តន៍*

១ ដោយប្រើពាក្យតែពីរឬបីម៉ាត់ ចូរប្រាប់ថាអ្វីជានិស្ស័យបាបរបស់លោកអដាំ និង នាងអេវ៉ា និង អំពើបាបរបស់លោកកាអ៊ីន? (គម្ពីរលោកុប្បត្តិ ៣:១១ និង ៤:៧)

..............................................................................................................................

ម្ដងហើយម្ដងទៀត យើងបានឃើញពីបញ្ហានៃអំពើបាប នៅពេលដែលយើងអានព្រះគម្ពីរ។ ព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យជាសំណេរ ដើម្បីដឹកនាំមនុស្សរបស់ទ្រង់ នៅក្នុងបទពិសោធន៍ដំបូងរបស់ពួកគេ (គម្ពីរនិក្ខមនំ ២០:១-១៧)។ ទ្រង់បានណែនាំលោកម៉ូសេបន្ថែមទៀត អំពីក្រឹត្យទាំងអស់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ហើយបានប្រាប់យ៉ាងច្បាស់ៗអំពីរបៀបដែលអាចបង់រំដោះអំពើបាប ដោយការដឹកនាំប្រជាជនអ៊ីស្រាអែល ដើម្បីថ្វាយយញ្ញបូជាដ៏ត្រឹមត្រូវ សម្រាប់លោះបាបដែលពួកគេបានប្រព្រឹត្តិ (គម្ពីរលេវី

វិន័យ ៤-៧)។ ទ្រង់ថែមទាំងបានកំណត់ពេលមួយថ្ងៃក្នុងមួយឆ្នាំ ដែលពួកសាសន៍អ៊ីស្រាអែលទាំងមូលត្រូវតែដោះស្រាយជាមួយនឹងអំពើបាបរបស់ខ្លួន (គម្ពីរលេវីវិន័យ ១៦)។ កណ្ឌគម្ពីរទាំងប្រាំកណ្ឌដំបូង ក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់គឺហៅថាកណ្ឌគម្ពីរក្រឹត្យវិន័យ ព្រោះតែកណ្ឌគម្ពីរទាំងនោះមានផ្ទុក ក្រឹត្យវិន័យទាំងអស់របស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ដើម្បីការរស់នៅឲ្យបានវិសុទ្ធ ព្រមទាំងផ្ទុកការណែនាំរបស់ទ្រង់ដើម្បីទទួលបានការអត់ទោសបាបរបស់ពួកគេ។

កណ្ឌគម្ពីរប្រវត្តិសាស្ត្រ ចាប់ពីគម្ពីរយ៉ូស្វេ ដល់គម្ពីរអេសធើរ បានកត់ត្រាអំពីការបរាជ័យដ៏គួរឲ្យសង្វេកនៃមនុស្សរបស់ព្រះជាម្ចាស់ ក្នុងការស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ កណ្ឌគម្ពីរទាំងនេះបានបង្ហាញអំពីការប្រព្រឹត្តអំពើអាក្រក់ឡើងវិញ ការមិនស្តាប់បង្គាប់ ភាពចចេស និង ការបះបោររបស់សាសន៍អ៊ីស្រាអែល ទៅកាន់ព្រះជាម្ចាស់ និង ក្រឹត្យវិន័យរបស់ទ្រង់។

## លំហាត់អនុវត្តន៍

២ ចូរប្រៀបធៀបគម្ពីរចៅហ្វាយ ២:៦-៧ ជាមួយនឹង គម្ពីរចៅហ្វាយ២:១០-១៩ ។ បន្ទាប់ពីការស្លាប់របស់លោកយ៉ូស្វេ តើប្រជារាស្ត្របានផ្លាស់ប្តូរយ៉ាងដូចម្តេច?

.......................................................................................................................................

៣ ចូរអានគម្ពីរចៅហ្វាយ ៣:៧,៩,១២,១៥; ៤:១; ៦:១។ តើរឿងអ្វីដែលកើតឡើងម្តងហើយម្តងទៀតនៅក្នុងខគម្ពីរទាំងនេះ?

.......................................................................................................................................

អ្នកនិពន្ធបានបង្ហាញពីទុក្ខព្រួយនៃអំពើបាបរបស់បុគ្គលៈ " ឱព្រះជាម្ចាស់អើយ! សូមប្រណីសន្តោសទូលបង្គំផង...សូមលុបលាងកំហុសទូលបង្គំអោយបានស្អាតទាំងស្រុង សូមជំរះទូលបង្គំអោយបានបរិសុទ្ធ រួចពីបាប!...ទូលបង្គំមានកំហុសតាំងពីកំណើតមកហើយ។" (គម្ពីរទំនុកតម្កើង ៥១:១-២,៥)។ ពួកព្យាការីក៏ទួញសោក ទាស់នឹងអំពីដែលជាមូលហេតុបង្កឲ្យមានការធ្លាក់ចុះរបស់សាសន៍អ៊ីស្រាអែល (គម្ពីរអេសេគាល ២៣ គម្ពីរយេរេមា ៥ គម្ពីរដានីយ៉ែល ៩:១-២៣)។

ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីបានកត់ត្រាអំពី អំពើក្បត់របស់លោកយូដាសអ៊ីស្ការីយ៉ុត (គម្ពីរម៉ាថាយ ២៦:១៤-១៦)។ ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីក៏បានបង្ហាញពីការរងទុក្ខរបស់ព្រះសង្គ្រោះនៃយើង ដែលបានទទួលយកបាបរបស់ពិភពលោកទាំងមូលដាក់លើអង្គទ្រង់ (គម្ពីរលូកា ២២:៣៩-៤៤ គម្ពីរយ៉ូហាន ១៩:១-៣, ១៨)។ គម្ពីរនេះមានរៀបរាប់អំពីរឿងដ៏រន្ធត់របស់លោកអាណាណាស និង សាភីរ៉ា (គម្ពីរកិច្ចការ ៥:១-១១)។ ភស្តុតាងដ៏ស្តែងៗមួយនៃធាតុពិតរបស់អំពើបាប គឺមានកត់ត្រាទុកនៅក្នុងគម្ពីររ៉ូម ១:១៨-៣២។ ខាងក្រោមនេះគឺជារបៀបដែលអំពើបាបត្រូវបានព្រះគម្ពីររៀបរាប់ៈ

> ដោយពួកគេយល់ថា មិនបាច់ស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់ ព្រះអង្គក៏បណ្តោយគេទៅតាមគំនិតឥតពិចារណារបស់ខ្លួន គឺអោយគេប្រព្រឹត្តអំពើដែលមិនត្រូវប្រព្រឹត្ត។ ចិត្តរបស់ពួកគេពោរពេញដោយគំនិតទុច្ចរិតគ្រប់យ៉ាង គំនិតអាក្រក់ គំនិតលោភលន់ គំនិតពាល ពេញទៅដោយចិត្តច្រណែនឈ្នានីស ចង់សម្លាប់គេ ឈ្លោះប្រកែក ល្បិចកិច្ចកល និងអបាយមុខ។ ពួកគេចូលចិត្ត

បរិហារកេរ្តិ៍គ្នា និយាយដើមគ្នា តាំងខ្លួនជាសត្រូវនឹងព្រះជាម្ចាស់ មានចិត្តកំរោលឃោរឃៅ មានអំនួតអួតបំប៉ោង ប្រសប់ខាងប្រព្រឹត្តអំពើអាក្រក់ មិនស្តាប់បង្គាប់ឪពុកម្តាយ។ ពួកគេជាមនុស្សល្ងីល្ងើមានចិត្តមិនទៀង ជាមនុស្សអត់ចិត្ត មិនចេះអាណិតអាសូរ។ ពួកគេស្គាល់ការវិនិច្ឆ័យរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ស្រាប់ហើយថា អ្នកណាប្រព្រឹត្តបែបនេះនឹងត្រូវទទួលទោសដល់ស្លាប់។ គេមិនត្រឹមតែប្រព្រឹត្តខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងយល់ស្របជាមួយអ្នកដែលប្រព្រឹត្តអំពើបែបនោះផងដែរ។ (ខ២៨ ដល់ខ ៣២)

## *លំហាត់អនុវត្តន៍*

៤ ចូរឲ្យនិយមន័យពីអំពើបាបតាមអ្វីដែលបានរៀបរាប់នៅក្នុងគម្ពីរ១យ៉ូហាន ៥:១៧ និង តាមការពិភាក្សារបស់យើង។

..........................................................................................................................

# ឃើញមាននៅក្នុងភាពចាំបាច់នៃរាជរដ្ឋាភិបាល

ព្រះគម្ពីរមិនត្រឹមតែបានបង្ហាញយើងអំពីឧទាហរណ៍ជាច្រើននៃធាតុពិតរបស់អំពើបាបប៉ុណ្ណោះទេ តែថែមទាំងបានផ្តល់ភស្តុតាង តាមរយៈភាពចាំបាច់នៃរាជរដ្ឋាភិបាលដែលមិនអាចចៀសបាន នៅក្នុងសង្គមរបស់យើង។ នៅក្នុងគម្ពីរចៅហ្វាយ ២១:២៥ បានចែកថា៖ " នៅគ្រានោះ ស្រុកអ៊ីស្រាអែលគ្មានស្តេចសោយរាជ្យទេ ម្នាក់ៗធ្វើអ្វីៗតាមតែខ្លួនយល់ឃើញ។" សូម្បីនៅគ្រានោះ ព្រះជាម្ចាស់បានប្រើប្រាស់ពួកចៅហ្វាយដើម្បីដឹកនាំជនជាតិអ៊ីស្រាអែល ដោយយោងទៅតាមទិសដៅរបស់ទ្រង់ ប៉ុន្តែនៅក្នុងគម្ពីរ១សាំយូអែល ៨ យើងឃើញថា ជនជាតិអ៊ីស្រាអែលបានសុំឲ្យលោកសាំយ៉ូអែល តែងតាំងស្តេចមួយអង្គដើម្បីដឹកនាំពួកគេ។ ពួកគេចង់មានរាជរដ្ឋាភិបាលដូចជាជាតិសាសន៍នានាដែលនៅជុំវិញគេដែរ (ខ៥) ។ ដោយសារតែប្រជាជនមិន សុខចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់ទេ នោះនាំមានតម្រូវការរាជរដ្ឋាភិបាលមួយជាចាំបាច់។

ពេលខ្លះមនុស្ស នឹកស្រម៉ៃចង់បានរាជរដ្ឋាភិបាលមួយដែលគេហៅថា "យូតូភា" (Utopia) (ដែនដីសុខក្សេមក្សាន្ត ) ដែលបានកន្លែងមួយ ឬ ប្រទេសមួយ មាននៅក្នុងឧត្តមគតិ ដែលមានភាពយុត្តិធម៌ និងភាពសុខដុមយ៉ាងល្អ ឥតខ្ចោះនៅក្នុងសង្គម។ នៅក្នុងយូតូភា មនុស្សគ្រប់គ្នាធ្វើរឿងដែលគេត្រូវធ្វើ រួមចំណែកនៅក្នុងសុខមាលភាព របស់អ្នកដទៃផ្សេងទៀត ហើយរីករាយជាមួយនឹងរឿងល្អៗក្នុងជីវិតយ៉ាងពេញបរិបូរណ៌។ ទោះជាយ៉ាងណា សង្គមដ៏សុខក្សេមក្សាន្តមួយនេះមិនអាចកើតមាននៅលើផែនដីនេះបានឡើយ។ មនុស្សលោកមាននិស្ស័យ អាត្មានិយម និង បះបោរ។ អំពើបាបគឺជាធាតុពិតនៃជីវិត ដែលយើងត្រូវប្រឈមមុខជាមួយជារៀងរាល់ថ្ងៃ។ គ្មាននរណាម្នាក់អាចគេចផុតពីឥទ្ធិពលរបស់វាបានឡើយ។ ផលវិបាកដ៏គួរឲ្យព្រឺព្រួចក្រំនៃអំពើបាប ត្រូវបានផ្សព្វផ្សាយនៅក្នុងកាសែត និង តាមរយៈវិទ្យុ និង បណ្តេញផ្សព្វផ្សាយធំៗដទៃទៀត ដែលបង្ហាញយ៉ាងច្បាស់ពីតម្រូវការចាំបាច់នៃការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលនៅក្នុងសង្គមរបស់យើង។

អំពើបាបគឺមានពិត។ វាមិនមែនជាលទ្ធផលនៃអបិយជំនឿ ឬ កង្វះការអប់រំនោះទេ។ វាគឺជាលទ្ធផលដែលបានមកពីនិស្ស័យរបស់មនុស្សប្រុសស្រីដែលរស់នៅទាស់ប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ និង ផ្អែកទៅលើបំណងចិត្តដ៏អាក្រក់របស់ពួកគេ។

## *លំហាត់អនុវត្តន៍*

៥ ចូរប្រាប់ពីភស្តុតាងពីរយ៉ាង នៃធាតុពិតរបស់អំពើបាប ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ព្រមទាំងឲ្យឧទាហរណ៍ សម្រាប់ភស្តុតាងនីមួយៗផងដែរ។

# ខ. ដើមកំណើតនៃអំពើបាប

អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ទស្សនវិទូបានធ្វើការវែងញែក តើអំពីបាបគឺមានតាំងពីដើមរៀងមក ហើយតែងតែមានវត្តមាននៅជាមួយនឹងការល្អ ដែរឬអត់។ អ្នកខ្លះបានធ្វើការសន្និដ្ឋានថា ការប្រជែងគ្នារវាងភាពត្រឹមត្រូវ និង ភាពមិនត្រឹមត្រូវមានតាំងដើមរៀងមក ហើយនឹងបន្តទៅមុខទៀតអស់កល្បជានិច្ច។ តើធ្លាប់មានពេលមួយដែលមានតែការល្អកើតឡើងដែរឬទេ? ប្រសិនបើមាន តើនៅពេលណា ដែលអំពើបាបចាប់ផ្ដើមបង្ហាញខ្លួនឡើង? ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងនេះ យើងត្រូវក្រឡេកទៅមើលលើការសិក្សា អំពីដើមកំណើតរបស់អំពើបាប នៅក្នុងសាកលលោក និង នៅក្នុងពូជអម្បូរមនុស្ស។

## នៅក្នុងសាកលលោក

**វត្ថុបំណងទី២.** *រៀបរាប់យ៉ាងត្រឹមត្រូវអំពីដើមកំណើតនៃអំពើបាប។*

នៅក្នុងមេរៀនទី៥ យើងបានពិភាក្សាអំពីអំពើបាបរបស់ពួកទេវតា ដែលនាំទៅរកការធ្លាក់ចុះរបស់ពួកគេ និង អំពីអ្វីដែលបទគម្ពីរបានថ្លែងអំពីដើមកំណើតរបស់អំពើបាបនៅក្នុងសាកលោក។ ចូរយើងរំឭកយ៉ាងសង្ខេបពីការពិតទាំងនេះឡើងវិញ ដើម្បីឃើញពីរបៀបដែលការនេះទាក់ទងនឹងការរាលត្បាតអំពើបាបទៅក្នុងពូជមនុស្ស។ ដំបូងយើងត្រូវអានមេរៀនទី៥ ឡើងវិញ នៅក្នុងចំណុចមួយដែលមានចំណងជើងថា "លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា" ។ ខាងក្រោមនេះជាការសង្ខេបខ្លីនៃចំណុចនោះ៖

១. ពួកទេវតា ត្រូវបានបង្កើតឡើងមកជាក្រុមភាវៈ មានភាពវិសុទ្ធ ល្អឥតខ្ចោះ និង មានបុគ្គលិកលក្ខណៈដែលមានឆន្ទៈបែរទៅរកព្រះអាទិកររបស់ពួកគេ។
២. ជាក់ស្ដែងពួកទេវតាមានអំណាចនៃការជ្រើសរើស និង ការយល់ដឹងពីផលវិបាកនៃការមិនស្ដាប់បង្គាប់។
៣. មានទេវតាមួយនៅក្នុងចំណោមពួកគេ បានទទួលបានតំណែងដ៏ខ្ពង់ខ្ពស់មួយ (គម្ពីរអេសេគាល ២៨:១២; គម្ពីរ២កូរិនថូស ៤:៤ គម្ពីរអេភេសូ ២:២)
៤. ជាក់ស្ដែង សាតាំងគឺជាអ្នកដឹកនាំការបះបោរតាំងពីដំបូងរៀងមក (គម្ពីរយ៉ូហាន ៨:៤៤ គម្ពីរ១យ៉ូហាន៣:៨)។

៥. ដោយការមើលទៅលើពួកស្តេចនៅលើផែនដី ដែលហាក់បីដូចជាតំណាងឲ្យសាតាំង យើងសរុបមកថា អំពើបាបរបស់គេចាប់ផ្តើមជាមួយនឹងមហិចតា និង ភាពក្រអឺតក្រទម (អំណួត)។ (ចូរប្រៀបធៀប គម្ពីរអេសេគាល ២៨:១១-១៩ និង គម្ពីរអេសាយ១៤:១៣-១៤ ជាមួយនឹង គម្ពីរ១ធីម៉ូថេ ៣:៦)។

បទគម្ពីរនៅខាងលើនេះ ជួយយើងឲ្យយល់ថា សាតាំងមិនពេញចិត្តនឹងឋានៈរបស់ខ្លួនឯង នៅក្រោមព្រះជាម្ចាស់នោះទេ។ វាខ្វល់ខ្វាយ ជាមួយនឹងមហិចតារបស់ខ្លួន ជាជាងការគោរពបម្រើព្រះជាម្ចាស់។ ភាពស្រស់ស្អាតរបស់វាបាន បាំងភ្នែកវាដែលធ្វើឲ្យវាគិតថាវាអាចខ្ពស់លើសពីព្រះអាទិករ។ វាមានភាពអាត្មានិយម មានភាពទោមនស្ស និង ច្រណែន មិនត្រឹមតែចង់បានអ្វីដែលព្រះអាទិករបានប្រទានឲ្យវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចង់បានអ្វីដែលទ្រង់ទុកសម្រាប់អង្គទ្រង់ផ្ទាល់ទៀតផង។ អាការៈនៃអំពើបាបដែលយើងឃើញនៅក្នុងសាតាំង គឺពិតជាឫសគល់នៃអំពើបាបដែលមាននៅក្នុងពួកទេវតាអាក្រក់ផ្សេងទៀតដែរ។

ទាំងអស់នេះ គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងរាល់គ្នា ព្រោះ នៅពេលដែលសាតាំង និងពួកទេវតារបស់វា បះបោរប្រឆាំងនឹងព្រះជាម្ចាស់ អំពើបាបបានក្លាយទៅជាគោលការណ៍មួយនៅក្នុងជីវិតដែលមនុស្សត្រូវប្រឈមមុខនៅក្នុងសាកលលោកនេះ។ អំពើបាបរបស់ពួកគេជាតំណាងឲ្យភាពផ្ទុយគ្នាទៅនឹងព្រះវរបិតានៃស្ថានបរមសុខដែលប្រកបដោយសេចក្តីស្រឡាញ់របស់យើង។ គោលបំណងរបស់សាតាំងពេលនេះ គឺរារាំងផែនការរបស់ព្រះជាម្ចាស់ នៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងសាកលលោកនេះ។ សាតាំងជាមេដឹងនាំ ប្រព័ន្ធលោកីយ៍មួយដែលមានគោលជំហរ ទាស់នឹងព្រះជាម្ចាស់ និង ក្រឹត្យវិន័យរបស់ទ្រង់។

## លំហាត់អនុវត្តន៍

៦ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ ដែលទាក់ទងនឹងដើមកំណើតអំពើបាបនៅក្នុងសាកលលោក។

ក) ព្រះជាម្ចាស់បានចាត់ឲ្យមានអំពើបាបនៅក្នុងសាកលលោកនេះ ដើម្បីជាការសាកល្បងភាពស្មោះត្រង់នៃស្នាព្រះហស្តរបស់ទ្រង់ ទៅចំពោះទ្រង់។

ខ) អំពើបាបគឺជាគោលការណ៍ដ៏អស់កល្បជានិច្ច ដែលត្រូវបានរចនាឡើងដើម្បីផ្តល់លំនឹងទៅដល់គោលការណ៍នៃសេចក្តីល្អ។

គ) អំពើបាបបានចាប់ផ្តើមនៅពេលដែល ភាវៈដែលព្រះជាម្ចាស់បង្កើតមកនោះ បានជ្រើសរើសមិនស្តាប់បង្គាប់ព្រះអាទិកររបស់ពួកគេ ហើយដើរតាមផ្លូវរបស់ខ្លួនឯង។

ឃ) អំពើបាបបានចាប់កំណើតនៅក្នុងសាកលលោកនេះ នៅពេលដែលសាតាំងចង់បានឋានៈខ្ពស់ជាងគេ ដោយព្រោះតែមហិចតា និង អំណួតរបស់វា។

ង) អំណាចនៃការជ្រើសរើស គឺចាំបាច់ខ្លាំងណាស់សម្រាប់ទេវតា ក៏ដូចជាមនុស្សផងដែរ ដោយព្រោះតែព្រះជាម្ចាស់ មិនបានបង្ខំឲ្យនរណាម្នាក់មកថ្វាយបង្គំទ្រង់នោះទេ។

# នៅក្នុងអម្បូរមនុស្ស

ដូចដែលយើងបានឃើញហើយថា ព្រះជាម្ចាស់បានបង្កើតលោកអដាំមកដោយគ្មាននិស្ស័យបាបសោះឡើយ ទ្រង់បានដាក់គាត់នៅក្នុងបរិស្ថានមួយដែលសមស្រប និង បំពេញគ្រប់ទាំងតម្រូវការរបស់លោក។ ព្រះជាម្ចាស់ប្រទានឲ្យអដាំនូវគំនិតដ៏មានអំណាច និង ការល្បួងលជាច្រើនដើម្បីឲ្យលោកអាចចំណាយពេល និង កម្លាំងរបស់លោក។ ទ្រង់ក៏បានប្រទានឲ្យលោកអដាំមាន អ្នកជំនួយ និង ដៃគូដែលសមស្របម្នាក់គឺនាងអេវ៉ា។ បន្ទាប់មកព្រះអាទិករបានដាក់ក្រឹត្យវិន័យដ៏សាមញ្ញខ្លះៗ ដើម្បីសង្កេត និង ដាស់តឿនលោកអដាំ និងនាងអេវ៉ាអំពីផលវិបាកនៃការមិនស្តាប់បង្គាប់។ បន្ទាប់មកទ្រង់បានយាងចុះមកដើម្បីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងមនុស្សដំបូងទាំងពីរនាក់។

ការដាស់តឿនរបស់ព្រះជាម្ចាស់ទៅកាន់លោកអដាំ និង នាងអេវ៉ា ត្រូវបានចាត់ទុកជាការសាកល្បងដ៏សាមញ្ញមួយ។ នៅក្នុងចំណោម អភ័យឯកសិទ្ធិ និង ការប្រោសប្រទានដ៏ច្រើនអនេក ពួកគេត្រូវបានហាមឃាត់ពីរឿងមួយប៉ុណ្ណោះ៖ ផ្លែនៃដើមឈើមួយដើម។ ការសាកល្បងនេះ គឺត្រូវបានបង្កើតឡើងដើម្បីបង្ហាញពីការស្តាប់បង្គាប់ និង មិនស្តាប់បង្គាប់របស់ពួកគេទៅចំពោះបំណងព្រះហឫទ័យរបស់ទ្រង់។ លោកអដាំ និង នាងអេវ៉ា មិនត្រូវបង្កើតឡើងឲ្យដូចជាមនុស្សយន្ត ដើម្បីរស់នៅក្នុងសម្រាប់សិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយគ្មានជម្រើសអ្វីទាល់តែសោះចំពោះបញ្ហាមួយនេះឡើយ។ ឆន្ទៈរបស់ពួកគេត្រូវតែមានទំនោរទៅរកព្រះជាម្ចាស់ ប៉ុន្តែដោយសារតែពួកគេមានអំណាចក្នុងការសម្រេចចិត្តទទួលយក ឬ ច្រានចោលទំនោរមួយនេះ ពួកគេអាចប្រើប្រាស់ឆន្ទៈសេរីរបស់ពួកគេ ហើយធ្វើការជ្រើសរើសប្រកបដោយការពិចារណាមួយ។ សមត្ថភាពមួយនេះ គឺជាលក្ខខណ្ឌចាំបាច់មួយ នៃការសាកល្បងមួយនេះ។

សាតាំងគ្មានអ្នកល្បួងវាទេ នៅពេលដែលវាបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ប៉ុន្តែចំណែកឯមនុស្សវិញ គឺមាន។ មិនយូរប៉ុន្មាន ក្រោយពេលដែលព្រះជាម្ចាស់បានដាក់លោកអដាំ និង នាងអេវ៉ានៅក្នុងសួនអេដែន សាតាំងបានចូលទៅឯនាងអេវ៉ា ហើយបញ្ជាក់ថា ព្រះជាម្ចាស់កំពុងតែលាក់បាំងរឿងមួយដែលល្អប្រសើរ និង មានប្រយោជន៍ពីនាង និង លោកអដាំ។ គួរឲ្យកត់សំគាល់ថា នាងអេវ៉ាមិនបានជំទាស់ទៅនឹងការចោទប្រកាន់ដ៏ធ្ងន់ធ្ងរនេះទាស់នឹងព្រះជាម្ចាស់ឡើយ។ តាមពិតទៅ នៅពេលដែលសាតាំងចោទព្រះជាម្ចាស់ថាបានកុហកដោយថ្លែងថា "ទេ! អ្នកទាំងពីរនឹងមិនស្លាប់ទេ។" (គម្ពីរលោកុប្បត្តិ ៣:៤) នាងអេវ៉ាមិនបានជំទាស់ និង មិនបានថ្លឹងថ្លែងការនិយាយប្រឆាំងនឹងលក្ខណសម្បត្តិដ៏វិសុទ្ធរបស់ព្រះជាម្ចាស់នោះទេ។ ផ្ទុយទៅវិញ នាងបានគិតតែពីប្រយោជន៍ដែល*នាង* អាចនឹងទទួលបានពីការធ្វើតាមការណែនាំរបស់អ្នកល្បួងទៅវិញ។ វាបានទាក់ជាប់នឹងអារម្មណ៍របស់នាង ចំណង់របស់នាង និង មហិច្ឆតាដែលទើបនឹងកើតថ្មីរបស់នាង។

ដូច្នេះហើយ ដោយសកម្មភាពនៃឆន្ទៈរបស់នាងអេវ៉ា និងដោយសារតែការបោកបញ្ឆោតរបស់សាតាំង នាងក៏បានសម្រេចចិត្តធ្វើអ្វីដែលនាងចង់ ដោយមិនធ្វើអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យនោះឡើយ។ គម្ពីរលោកុប្បត្តិ ៣:១-៥ បានបង្ហាញថា នាងចង់ ១) បានអ្វីដែលព្រះជាម្ចាស់បានហាម ២) ដឹងពីអ្វីដែលព្រះជាម្ចាស់មិនបានបើកបង្ហាញ និង ៣) ក្លាយខ្លួនជាអ្វីដែលព្រះជាម្ចាស់មិនមានការបម្រុងទុកសម្រាប់នាងឡើយ។

ដូច្នេះនាងអេវ៉ាជ្រើសរើសខ្លួនឯង លើសព្រះជាម្ចាស់ នោះហើយគឺជាអំពើបាប។ នាងបានគិតអ្វីដែលនាងនឹងធ្វើរួចទៅហើយ។ ដោយមើលទៅលើផ្លែឈើនោះ យើងបានឲ្យហេតុផលថា ដោយសារតែផ្លែឈើនោះជាផ្លែឈើល្អ នោះគ្មានអ្វីខុសឆ្គងនោះទេ បើគ្រាន់តែបរិភោគវា។ នាងក៏បានឲ្យហេតុផលថា ដោយសារតែផ្លែឈើនោះវាស្រស់ស្អាត និង ឮថាអាចផ្តល់ការដឹងខុសត្រូវផងនោះ គ្រាន់តែបរិភោគប៉ុណ្ណឹង វាមិនខុសអ្វីនោះទេ។ ដូច្នេះហើយ នាងបានភ្លេចការពិតដ៏សំខាន់ជាងគេបំផុត ៖ *ព្រះជាម្ចាស់បានហាមឃាត់មិនឲ្យបរិភោគផ្លែឈើនោះ!* ដោយឃើញតែពីអ្វីដែលនាងចង់ឃើញ នាង និង លោកអដាំបានបរិភោគផ្លែឈើនោះដោយការមិនស្តាប់បង្គាប់នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងបើកចំហ។ ទោះបីជាពួកគេមានសតិបញ្ញាគ្រប់គ្រាន់នឹងឲ្យពួកគេយល់ពីផលវិបាកយ៉ាងណាក៏ដោយ ក៏ពួកគេមិនបានសូម្បីតែសួរថាតើព្រះជាម្ចាស់បានទទួលសិរីរុងរឿងដែរឬទេ ចំពោះសកម្មភាពរបស់ពួកគេនេះ។ ហេតុអ្វីបានជាពួកគេមិនពិចារណាឲ្យបានម៉ត់ចត់ជាងនេះ ចំពោះអ្វីដែលពួកគេធ្វើ?

ដូច្នេះបុព្វបុរសរបស់យើងមានចេតនាជ្រើសរើស ការមិនស្តាប់បង្គាប់តាមការដាស់តឿនរបស់ព្រះជាម្ចាស់។ ទោះបីជាពួកគេត្រូវបានសាតាំងល្បួងក៏ដោយ គ្មាននរណាបានបង្ខំពួកគេឲ្យប្រឆាំងការណែនាំរបស់ព្រះជាម្ចាស់នោះទេ ។ ទង្វើនៃការមិនស្តាប់បង្គាប់បែបនេះ បង្កើតបានទៅជាអំពើបាបនៅក្នុងអម្បូររបស់មនុស្ស (សូមមើលនៅក្នុងគម្ពីររ៉ូម ៥:១២) និងឥរិយាបថដែលនាំឲ្យអំពើបាបបន្តនៅក្នុងនិស្ស័យរបស់មនុស្ស ។ ខ្ញុំបានដឹងពីវា ចំណែកអ្នកក៏ដូចគ្នាដែរ។ ដូច្នេះហើយ អំពើបាបបានចូលមកក្នុងពិភពលោក និង ជះឥទ្ធិពលអាក្រក់មកលើមនុស្សលោក បំផ្លាញទំនាក់ទំនងដែលប្រកបដោយព្រះពររបស់មនុស្សជាមួយនឹងព្រះជាម្ចាស់។ អំពើបាបនៅតែបន្តឥទ្ធិពលរបស់វានៅលើ កូនចៅជំនាន់ក្រោយរបស់លោកអដាំ។ មនុស្សគ្រប់រូប ទទួលបានកេរ្តិ៍មរតកនៃនិស្ស័យបាបនេះពីលោកអដាំ ហើយបើមិនកែតម្រូវនោះទេ នឹងនាំទៅរកសេចក្តីស្លាប់ខាងវិញ្ញាណជាក់ជាមិនខាន។

## លំហាត់អនុវត្តន៍

៧ ចូរអានគម្ពីរលោកុប្បត្តិ ៣:២២-២៣ និង គម្ពីររ៉ូម ៥:១២ ហើយឆ្លើយសំណួរទាំងនេះ៖

ក) តើអ្វីជាលទ្ធផលនៃអំពើបាបរបស់លោកអដាំ ទាក់ទងទៅនឹងជីវិតផ្ទាល់ខ្លួនរបស់គាត់?

.......................................................................................................................

ខ) តើអ្វីជាលទ្ធផល ទៅចំពោះកូនចៅជំនាន់ក្រោយរបស់លោកអដាំ?

.......................................................................................................................

៨ ដោយឆ្លើយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរបកស្រាយពីមូលហេតុដែលសក្តិសមឲ្យព្រះជាម្ចាស់ ដាក់ទោសលោកអដាំ និង នាងអេវ៉ា ហើយតាមរយៈពួកគាត់ទាំងពីរនាក់ បានឆ្លងដល់អម្បូរមនុស្សទាំងមូល ។

# គ. និស្ស័យរបស់អំពើបាប

**វត្ថុបំណងទី៣.** *ស្គាល់ពីទិដ្ឋភាពនៃអំពើបាប។*

តើវាមិនងាយទេឬអី បើអំពើបាបគឺជាសារធាតុមានរូប ដែលយើងអាចធ្វើការញែកចេញបាននោះ? យើងអាចអញ្ជើញអ្នកស្រាវជ្រាវ ពីរបីនាក់មកដើម្បីរកមើលសារធាតុគីមី ថ្នាំ ឬ សេរ៉ូមដើម្បីបំផ្លាញវាបាន។ បន្ទាប់មក ក្រុមអ្នកជំនាញអាចធ្វើដំណើរពីសហគមន៍មួយទៅសហគមន៍មួយ ដើម្បីចាក់ថ្នាំនោះ ដែលនឹងអាចបញ្ចប់អំណាច និង ផលវិបាករបស់វាបាន។ មិនយូរប៉ុន្មាន សង្គមនឹងអាចផ្លាស់ប្តូរទាំងស្រុង ហើយមនុស្សអាចរស់នៅដើម្បីសសើរផតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់បាន។ យើងដឹងថា អំពើបាបមិនមែនជាមេរោគ ឬ ក៏ជាវីរុសនោះដែរ។ តើអ្វីជានិស្ស័យដ៏ពិតរបស់អំពើបាប?

យើងបានឃើញពីអត្ថន័យសង្ខេបនៃអំពើបាបនៅក្នុងទិដ្ឋភាពដំបូងបំផុតក្នុងមេរៀននេះហើយ វាគឺជាការមិនស្តាប់បង្គាប់ និង ការបរាជ័យក្នុងការប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាគឺជាអ្វីៗគ្រប់យ៉ាងដែលមនុស្សធ្វើខុស ។ វារាប់បញ្ចូលទាំង ការធ្វើអ្វីដែលមិនគួរធ្វើ និង មិនបានធ្វើអ្វីដែលយើងគួរតែធ្វើ។

ភាសាហេប្រឺនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ភាសាក្រិកដែលប្រើដើម្បីសរសេរ គម្ពីរសម្ព័ន្ធមេត្រីថ្មី បានប្រើប្រាស់ពាក្យយ៉ាងច្បាស់ៗ ដើម្បីរៀបរាប់អំពីសកម្មភាពនៃការធ្វើអំពើបាបទាស់នឹងព្រះជាម្ចាស់។ អ្នកប្រាជ្ញខាងព្រះគម្ពីរ ដែលបានសិក្សាការបង្កើតពាក្យ បានបកស្រាយពីផ្នត់គំនិតដែលនៅពីក្រោយការបង្កើតពាក្យទាំងនោះ។ ការសិក្សាពាក្យរបស់ពួកគេ បានផ្តល់ឲ្យយើងនូវការយល់ដឹងមួយអំពីអត្ថន័យនៃពាក្យថា *អំពើបាប។* ពាក្យនីមួយៗ បង្ហាញតាមរបៀបផ្សេងៗគ្នា អំពីសកម្មភាព ឬ ឥរិយាបថទដែលបង្ករឲ្យមានការមិនសព្វព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ចូរយើងក្រឡេកទៅមើលពាក្យខ្លះៗ ។ (ពាក្យដែលបានប្រើនៅក្នុងការបកប្រែគម្ពីរ ជំនាន់ថ្មី ប្រហែលជាមិនដូចទៅនឹងពាក្យដែលបកមកពីពាក្យហេប្រឺ និង ពាក្យក្រិក ដែលយើងរៀបរាប់ខាងក្រោមនេះទាំងស្រុងនោះទេ ។)

១. *អំពើរំលង* (គម្ពីររ៉ូម ៥:១៤-១៧, គកស២០១៦)។ យើងតែងតែឃើញ ផ្លាកសញ្ញាដែលសរសេរថា *ហាមចូល (រំលង)។* តើផ្លាកសញ្ញានោះមានន័យយ៉ាងដូចម្តេច? ការចូល ឬ រំលង មានន័យថា ការឆ្លងកាត់ ឬ បំពានកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកដទៃ។ នៅពេលដែលនរណាម្នាក់ ដាក់ផ្លាកសញ្ញាដូចនេះ ពួកគេមិនចង់ឲ្យនរណាម្នាក់ផ្សេងទៀតឆ្លងកាត់លើកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេឡើយ។ ដើម្បីរារាំងកុំឲ្យ មានការផ្លោះរំលង ពួកគេអាចនឹងបិទបាំងកន្លែងដែលជាកម្មសិទ្ធិរបស់គេ ឬ កំណត់ព្រំប្រទល់យ៉ាងច្បាស់។ ជារឿយៗ ពួកគេបានដាក់បន្ថែមនៅលើផ្លាកសញ្ញារបស់ពួកគេ នូវទោសនៃការផ្លោះរំលងនោះ។ ដូចគ្នាដែរ ព្រះជាម្ចាស់បានបង្កើតដែនកំណត់ខាងឯសីលធម៌ សម្រាប់មនុស្សដែលយើងរាល់គ្នាហៅថាច្បាប់នោះឯង។ នៅពេលដែលមនុស្សផ្លោះរំលង ឬ ឆ្លងកាត់លើដែនកំណត់ទាំងនោះ ពួកគេបានប្រព្រឹត្តិបាបហើយ ពួកគេប្រងើយកន្តើយចំពោះច្បាប់របស់ព្រះជាម្ចាស់ ។ ភាពគ្មានច្បាប់ទម្លាប់ គឺជាអំពើបាប (គម្ពីរ១យ៉ូហាន ៣:៤)។

២. *ខុសគោលដៅ* (គម្ពីរនិក្ខមនំ ២០:២០) ។ នៅពេលដែលមនុស្សធ្វើអំពើបាប ពួកគេបានបរាជ័យក្នុងការបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់ពួកគេ។ នៅក្នុងន័យនេះ អំពើបាបគឺជាការ *ខុសគោលដៅ* ។ ពួកគេធ្វើមិនដល់អ្វីដែលព្រះជាម្ចាស់ បានដាក់ផែនការសម្រាប់ពួកគេ។ *ការខុសគោលដៅ* គឺជាពាក្យមួយដែលទាក់ទងទៅនឹង ការបាញ់ធ្នូ នៅពេលដែលមនុស្សម្នាក់បាញ់មិនត្រូវចំណុចកណ្តាលនៃគោលដៅរបស់គេតម្រង់បាញ់ទៅនោះ។

៣. *ភាពអាត្មានិយម* (គម្ពីរទំនុកតម្កើង ១១៩:៣៦និង គម្ពីរ ភីលីព ២:៣) ។ ការមិនស្តាប់បង្គាប់លើកទីមួយ បានកើតឡើងដោយព្រោះតែភាពអាត្មានិយម ដ្បិតមនុស្សដំបូងបង្អស់ គេចង់បានអ្វីដែលគេគិតថា ព្រះជាម្ចាស់បានបដិសេធជាមួយនឹងពួកគេ។ វាបានទាក់ទាញ *ភាពឥតប្រយោជន៍* និង *អំណួត* របស់ពួកគេ។

៤. *ការបះបោរ* (គម្ពីរនិក្ខមនំ ២៣:២១ គម្ពីរ១សាំយ៉ូអែល ២៤:១១) ។ ការបះបោរគឺជាការមិនស្តាប់បង្គាប់ ឬ ការប្រឆាំងទាស់នឹងសិទ្ធិអំណាចរបស់នរណាម្នាក់។ ការបះបោរ គឺជា *ការចាកចេញឆ្ងាយ* ពីច្បាប់របស់ព្រះជាម្ចាស់។ លោកអេសាយ បានបង្ហាញពីការនេះ ដោយមានប្រសាសន៍ថា៖ "កាលពីមុនយើងទាំងអស់គ្នាសុទ្ធតែវង្វេងដូចចៀមដែលបែកចេញពីហ្វូង
ម្នាក់ៗដើរតាមផ្លូវរបស់ខ្លួនផ្ទាល់" (គម្ពីរអេសាយ ៥៣:៦) ។ នេះគឺគ្រាន់តែជាអ្វីដែលមនុស្សធ្វើនៅក្នុងពេលសព្វថ្ងៃនេះតែប៉ុណ្ណោះ។ គ្រប់គ្នាចង់ "ធ្វើរឿងរបស់ខ្លួនឯង" ដើរតាមបំណងចិត្តផ្ទាល់ខ្លួន។ រឿងដូចគ្នានេះ គឺកើតមានដូចគ្នានៅក្នុងសហគមន៍ និង ប្រទេសជាតិទាំងមូលផងដែរ។ មនុស្សមិនចង់ដើរតាមមាគ៌ាដែលព្រះជាម្ចាស់បានកំណត់ទុកសម្រាប់ពួកគេឡើយ។

៥. *ការប្រឡាក់* (គម្ពីរយ៉ាកុប ១:២៧ គកស២០១៦) ។ នៅពេលដែលមនុស្សធ្វើអំពើបាបដោយចេតនា ពួកគេបានដឹងច្បាស់ពីការធ្វើខុសរបស់ផងគេ ដ្បិតមនសិការរបស់ពួកគេ ថ្កោលទោសពួកគេ។ អារម្មណ៍មានកំហុស នេះហើយដែលត្រូវបានដាស់ឡើងដោយអំពើបាប ធ្វើឲ្យពួកគេដឹងពីភាពប្រឡាក់របស់ពួកគេ (ភាពមិនស្អាត)។ ពួកគេមានអារម្មណ៍កខ្វក់។ នោះគឺជាមូលហេតុដែលបទគម្ពីរ ថ្លែងពីតម្រូវការ នូវ *ការលាងសម្អាត* ឲ្យអស់ការប្រឡាក់នៃអំពើបាបនេះ (គម្ពីរទំនុកតម្កើង ៥១:២, ៧ គម្ពីរ១យ៉ូហាន ១:៧,គកស២០១៦)

សង្ខេបមកយ៉ាងខ្លី អំពើបាបគឺជាការបរាជ័យរបស់ស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ក្នុងការស្តាប់បង្គាប់តាមច្បាប់របស់ទ្រង់។ អ្វីក៏ដោយ ឲ្យតែមិនមានគោលដៅក្នុងការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺជាអំពើបាប (គម្ពីររ៉ូម ៣:២៣)។ អ្វីក៏ដោយ នៅក្នុងយើងរាល់គ្នាដែលមិនបង្ហាញ ឬ ផ្ទុយពីលក្ខណសម្បត្តិដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ គឺអំពើបាប។

# *លំហាត់អនុវត្តន៍*

៩ ចូរផ្គូផ្គងពាក្យដែលតំណាងឲ្យទិដ្ឋភាពមួយនៃអំពើបាប (ខាងស្ដាំ) ទៅនឹងនិយមន័យដែលត្រឹមត្រូវសម្រាប់ពាក្យនីមួយៗ (ខាងឆ្វេង)។

........ក) ការចង់ដើរតាមផ្លូវផ្ទាល់ខ្លួន ដោយ មិនចង់ចុះចូលជាមួយមាគ៌ាព្រះជាម្ចាស់ឡើយ។

........ខ) ជាអ្វីដែលត្រូវការការលាងសម្អាត។

........គ) បរាជ័យក្នុងការបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅក្នុងជីវិត។

........ឃ) ការឆ្លងកាត់លើដែនកំណត់ដែលព្រះជាម្ចាស់បានហាមឃាត់។

........ង) ការធ្វើទាស់នឹងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ ការចាកចេញឆ្ងាយពីច្បាប់របស់ព្រះជាម្ចាស់។

១) អំពើរំលង

២) ខុសគោលដៅ

៣) ភាពអាត្មានិយម

៤) ការបះបោរ

៥) ការប្រឡាក់

# ឃ. ផលវិបាកនៃអំពើបាប

**វត្ថុបំណងទី៤.** *រៀបរាប់អំពីផលវិបាកនៃអំពើបាប។*

គម្ពីរលោកុប្បត្តិជំពូក៣ បានរំឭកឡើងវិញនូវផលវិបាកនៃអំពើបាបដំបូងគេបង្អស់។ ពិតដូចជាអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលថា៖ "តែមិនត្រូវបរិភោគផ្លែឈើពីដើម ដែលនាំអោយស្គាល់ល្អស្គាល់អាក្រក់ឡើយ" ហើយទ្រង់ថែមទាំងព្រមានទៀតថា៖ "ដ្បិតថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន" (គម្ពីរលោកុប្បត្តិ ២:១៧)។ ដោយមិនគោរពតាមការព្រមានរបស់ព្រះជាម្ចាស់ និង ដោយការយកអ្វីដែលទ្រង់បានហាម លោកអដាំ និង នាងអេវ៉ាមិនអាចរំពឹងទុកថានឹងទទួលបានអ្វីទៀត ក្រៅពីផលវិបាកដែលទ្រង់បានសន្យានោះឡើយ។ ចូរក្រឡេកមើលបន្តិច ទៅលើផលវិបាកធំៗនៃអំពើបាបដើមដំបូងបង្អស់របស់មនុស្សជាតិ។

## សម្ព័ន្ធភាពប្រេះស្រាំជាមួយនឹងព្រះជាម្ចាស់

ការយល់ដឹង និង ការទទួលស្គាល់ថា ពួកគេបានមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយចេតនារបស់ពួកគេ បាននាំមកឲ្យលោកអដាំ និងនាងអេវ៉ានូវ អារម្មណ៍ថាមានទោសភ្លាមៗ។ ភាពគ្មានទោសរបស់ពួកគេបានបាត់ទៅហើយ ហើយមនសិការរបស់ពួកគេបានចោលទោសចំពោះទង្វើរបស់ពួកគេ។ ពួកគេទទួលអារម្មណ៍ដឹងពីភាពអាក្រាតរបស់ខ្លួន ចំពោះមុខគ្នាទៅវិញទៅមក និង នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ផងដែរ ហើយពួកគេបានព្យាយាមលាក់ខ្លួនពីព្រះជាម្ចាស់ជាមួយនឹងភាពអាម៉ាស់។ នៅពេលដែលទ្រង់ ឲ្យពួកគេប្រឈមមុខនឹងអ្វីដែលពួកគេបានធ្វើ ពួកគេបានព្យាយាមបន្ទោសគ្នាទៅវិញទៅមក។ លោកអដាំបន្ទោសនាងអេវ៉ា ហើយនាងអេវ៉ាបានបន្ទោសសត្វពស់ (គម្ពីរលោកុប្បត្តិ ៣:១២-១៣) ហើយជាមួយនឹងការសារភាពបាបដ៏ខ្លោចផ្សាមួយនេះ

សម្ព័ន្ធភាពផ្ទាល់ខ្លួន ដ៏ស្រស់ស្អាតជាមួយព្រះជាម្ចាស់ក៏ត្រូវបានបញ្ចប់ ។ ពួកគេបានស្លាប់ ខាងឯវិញ្ញាណបាត់ទៅហើយ (គម្ពីរលោកុប្បត្តិ ២:១៧) និង ត្រូវបានបណ្តេញចេញពីសួនច្បារអេដែន ឲ្យទៅរស់នៅក្នុងជីវិតមួយដែលខុសស្រឡះ ពីអ្វីដែលដែលពួកគេបានស្គាល់នៅក្នុងពេលនោះ។

## និស្ស័យដែលពេញដោយបាប

អំពើបាបរបស់លោកអដាំ និង នាងអេវ៉ា មិនត្រឹមតែបានបំផ្លាញដួងចិត្តរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏បានបំផ្លាញដួងចិត្តរបស់កូនចៅជំនាន់ក្រោយទាំងអស់របស់ពួកគេផងដែរ។ ព្រះគម្ពីរបានថ្លែងថា អំពើបាបតែមួយរបស់ពួកគេ គឺជាគោលការណ៍ដ៏ពុករលួយមួយដែលបានបន្តមកឲ្យមនុស្សគ្រប់គ្នាដែលជាកូនចៅជំនាន់ក្រោយ និង ទៅដល់មានគ្រប់គ្នាផងដែរ (គម្ពីររ៉ូម ៥:១២) ។ ដូច្នេះ ពិភពលោកទាំងមូលបានធ្លាក់នៅក្រោមអំណាចរបស់អំពើបាប (គម្ពីរកាឡាទី ៣:២២) ហើយជាមួយនឹងចំណងមួយនេះ យើងក៏បានក្លាយជា "មនុស្សជាប់ក្នុងសេចក្តីខ្ញាល់" (គម្ពីរអេភេសូ ២:៣ ពគប១៩៥៤) ។ និស្ស័យបាបនេះ រារាំងមនុស្សមិនឲ្យផ្តាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ មនុស្សគ្រប់គ្នាធ្វើអ្វីដែលពួកគេធ្វើ ក៏ព្រោះតែនិស្ស័យដ៏ពុករលួយរបស់ពួកគេ ព្រោះតែអ្វីដែលជាពួកគេ។

ព្រះគម្ពីរបានថ្លែងថា ពួកយើងកើតមកជាមួយនឹងនិស្ស័យដ៏ពុករលួយមួយនេះ (គម្ពីរទំនុកតម្កើង ៥១:៥)។ យើងអាចនឹងគិតថា បុត្ររបស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ ហើយគ្មាននិស្ស័យបាបអ្វីទាល់តែសោះ។ ទោះជាយ៉ាងណា នៅពេលដែលយើងមើលទៅលើបងប្អូនប្រុសស្រី ឈ្លោះប្រកែកគ្នា យើង ដឹងថា ភាពអាត្មានិយម គឺជាទិដ្ឋភាពមួយនៅក្នុងនិស្ស័យរបស់មនុស្ស។ ទំនោររបស់ក្មេងដែលចេះតែចង់មិនស្តាប់បង្គាប់ក៏បានមកពីនិស្ស័យបាបរបស់ពួកគេផងដែរ។

## *លំហាត់អនុវត្តន៍*

---

១០ ចូរផ្គូផ្គងបទគម្ពីរ (ខាងឆ្វេង) ទៅជាមួយនឹងទិដ្ឋភាពមួយរបស់យើងដែលត្រូវបានធ្វើឲ្យពុករលួយដោយអំពើបាប (ខាងស្តាំ)។

| | | | |
|---|---|---|---|
| .........ក) | គម្ពីរ១ធីម៉ូថេ ៤:២ គម្ពីរទីតុស ១:១៥ | ១) | សតិបញ្ញា |
| .........ខ) | គម្ពីររ៉ូម ១:២៨ គម្ពីរ១កូរិនថូស ២:១៤ | ២) | វេទនារម្មណ៍ និង អារម្មណ៍ |
| | គម្ពីរ២កូរិនថូស ៤:៤ គម្ពីរអេភេសូ ៤:១៨ | ៣) | ឆន្ទៈ |
| .........គ) | គម្ពីរអេភេសូ ២:១,៥; គម្ពីរកូឡុស ២:១៣,១៨ | ៤) | មនសិការ |
| .........ឃ) | គម្ពីរយេរេមា ១៧:៩-១០ គម្ពីរអេភេសូ ៤:១៩ | ៥) | វិញ្ញាណ (បានស្លាប់ទៅហើយ) |
| .........ង) | គម្ពីររ៉ូម ១:២៨; ៧:១៨-២០ | | |

បទសំណេរទាំងអស់នេះ បង្ហាញយើងថា គ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងជីវិតរបស់មនុស្សជាតិគឺ ត្រូវបានធ្វើឲ្យខូចបង់ដោយអំពើបាប ហើយនៅក្នុងស្ថានភាពបែបនេះ មនុស្សមិនអាចធ្វើអ្វីៗ ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ។ នេះមិនមែនមានន័យថា មនុស្សដែលគ្មានព្រះជាម្ចាស់មិនអាចធ្វើ ឬ យល់ពីទង្វើល្អ និង មេត្តាធម៌ឡើយ។ នោះមានន័យថាមនុស្សមិនអាចធ្វើអ្វីឲ្យសមនឹងទទួលបានការគាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ ដរាបណាគេត្រូវបានប្រោសឲ្យរស់ ខាងឯវិញ្ញាណជាមុនសិន។ ភាពដូចនឹងព្រះជាម្ចាស់ នៅក្នុងពួកគេត្រូវបានបង្ខូចអស់ទៅហើយ។

ពួកយើងមិនត្រឹមតែទទួលរងផលវិបាក ដែលបានមកពីអំពើបាបរបស់លោកអដាំ និង ឥទ្ធិពលនៃនិស្ស័យបាបដែលយើងទទួលបានពីគាត់នោះទេ យើងក៏បានទទួលរងផលវិបាកនៃអំពើបាបរបស់ខ្លួនយើងផ្ទាល់ផងដែរ។ ប្រសិនបើខ្ញុំខ្ជិល ហើយមិនធ្វើការ ខ្ញុំនឹងទទួលរងនូវផលវិបាក (ហើយគ្រួសាររបស់ខ្ញុំក៏ដូចគ្នាដែរ)។

ជាញឹកញយ យើងត្រូវតែរងទុក្ខមិនត្រឹមតែលទ្ធផលនៃអំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏មានផលវិបាកនៃអំពើបាបរបស់អ្នកដទៃផងដែរ។ប្រជាជនដែលរស់នៅក្នុងប្រទេសដែលមានមន្ត្រីក្នុងរដ្ឋាភិបាលជាមនុស្សពុករលួយ មិនរីករាយជាមួយនឹងពរជ័យដែលរដ្ឋាភិបាលល្អត្រឹមត្រូវអាចផ្តល់ឲ្យនោះទេ។ កុមារដែលមានឪពុកជាមនុស្សប្រមឹក អាចរងការបំពានដែលអាចជាលទ្ធផលដែលបានមកពីគំនិតដែលបំពុលដោយស្រានោះ។ មនុស្សដែលស្លាប់នៅក្នុងគ្រោះថ្នាក់ចរាចរណ៍ ក៏ដោយព្រោះតែមនុស្សស្រវឹង។ សង្គមទូទៅ រងការបំពានពីសំណាក់ឧក្រិដ្ឋជន ហើយត្រូវបង់ថ្លៃសំរាប់ការចាប់មនុស្សទាំងអស់នោះឃុំឃាំងថែមទៀតផង។

នៅក្នុងមេរៀនទី៦ យើងបានឃើញថា ទិដ្ឋភាពល្អរបស់មនុស្សជាតិគឺត្រូវតែទទួលបានការកោតសរសើរ តែពេលនេះសូមមើលទៅលើទិដ្ឋភាពដែលគួរឲ្យខ្លោចផ្សាវិញ។ មនុស្សជាតិដែលគ្មានព្រះជាម្ចាស់ គឺពុករលួយ។ ស្របពេលដែលយើងកំពុងរំកិលខិតចូលជិតដល់ថ្ងៃចុងក្រោយ យើងអាចរំពឹងថានឹងបានឃើញស្ថានភាពដ៏អាក្រក់នៅគ្រប់ទីកន្លែង។ តាមរយៈការជំរុញពីព្រះវិញ្ញាណ លោកសាវ័កប៉ូលបានសរសេរពាក្យពេចន៍ទាំងនេះ៖

> អ្នកត្រូវដឹងអោយច្បាស់ថា នៅពេលចុងក្រោយបង្អស់ នឹងមានគ្រាលំបាក មនុស្សម្នានឹងមានចិត្តអាត្មានិយម ស្រឡាញ់ប្រាក់ ក្រអឺតក្រទមអួតខ្លួន ប្រមាថព្រះជាម្ចាស់ មិនស្ដាប់បង្គាប់ឪពុកម្ដាយ រមិលគុណ បំផ្លាញអ្វីៗដែលជាសក្ការៈ គេជាមនុស្សអត់ចិត្ត គ្មានអធ្យាស្រ័យ និយាយមួលបង្កាច់ មិនចេះទប់ចិត្ត ឃោរឃៅ ស្អប់អំពើល្អ ជាមនុស្សមានចិត្តក្បត់ ឆាប់ច្រឡោត អួតបំប៉ោង ចូលចិត្តសប្បាយជាជាងស្រឡាញ់ព្រះជាម្ចាស់។ គេសំដែងអាការៈខាងក្រៅជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ ប៉ុន្តែ គេបដិសេធមិនទទួលស្គាល់ឫទ្ធានុភាព ដែលបានមកពីការគោរពប្រណិប័តន៍ព្រះអង្គនោះឡើយ។ ចូរចៀសចេញអោយឆ្ងាយ ពីមនុស្សប្រភេទនេះទៅ។(១ធីម៉ូថេ៣:១-១៥)

## *លំហាត់អនុវត្តន៍*

១១ តើប្រយោគណាមួយនៅខាងក្រោមនេះដែលបកស្រាយអំពីផលវិបាកនៃអំពើបាបបានល្អជាងគេ?

ក) យើងរងទុក្ខសព្វថ្ងៃនេះ មិនមែនគ្រាន់តែ ដោយសារអំពើបាបរបស់លោកអដាំ និង និស្ស័យបាបដែលយើងបានស្នងនោះទេ ប៉ុន្ដែក៏ជាផលវិបាកដែលបានមកពីអំពើបាបរបស់អ្នកដទៃផ្សេងទៀតផងដែរ។

ខ) មនុស្សគ្រប់គ្នា ទទួលរងផលវិបាកនៃអំពើបាបផ្ទាល់ខ្លួនរបស់គេ ប៉ុន្ដែអំពើបាបរបស់គេគ្មានឥទ្ធិពលទៅលើជីវិតរបស់អ្នកដទៃឡើយ។

គ) ផលវិបាកនៃអំពើបាបនឹង កាត់បន្ថយនៅគ្រាចុងក្រោយ ពេលដែលមនុស្សទទួលបានការបំភ្លឺ។

## ទំនួលខុសត្រូវខាងឯរូបកាយ

លោកអដាំ និង នាងអេវ៉ានៅក្នុងសួនអេដែន មិនដែលស្គាល់ជំងឺឈឺថ្កាត់អ្វីឡើយ។ មេរោគវីរុស និង ជំងឺគ្រប់ប្រភេទទាំងអស់ បានលេចឡើងជាលទ្ធផលនៃអំពើបាប និង ត្រូវបានគេឃើញនៅក្នុងទំនាក់ទំនងរវាងអំពើបាប និង ការកាត់ទោស (គម្ពីរនិក្ខមនំ ១៥:២៦ គម្ពីរទុតិយកថា ២៨:៥៨-៦២)។ ការឈឺចាប់ ភាពអស់កម្លាំង និង ការបាក់បែករូបកាយ គឺជាទិដ្ឋភាពនៃដំណើរការដែលបានចាប់ផ្ដើមឡើងដោយអំពើបាប ដែលចុងក្រោយនឹងនាំទៅរកសេចក្ដីស្លាប់ខាងឯរូបកាយ (គម្ពីរលោកុប្បត្តិ ៣:១៦-១៩) ។ ការពិត សេចក្ដីស្លាប់នៅតោងជាប់ជាមួយមនុស្ស គឺជាលទ្ធផលនៃការធ្លាក់ចុះរបស់មនុស្សជាតិ។ ដំណើរការនៃការរស់នៅក៏បានកំណត់ដោយ ភាពផ្ទុយគ្នារបស់សាតាំងទៅនឹងការខិតខំប្រឹងប្រែងរបស់យើង ដើម្បីបានឆ្ពោះទៅដល់ការរស់នៅសម្រាប់ព្រះជាម្ចាស់ និង បានផ្ដាប់ព្រះហឫទ័យទ្រង់ផង (គម្ពីរលោកុប្បត្តិ ៣:១៥)។

## បរិស្ថានដ៏កាចសាហាវមួយ

ដោយសារតែបណ្ដាសារដែលបានមកពីអំពើបាប សាកលលោកទាំងមូលក៏ត្រូវបានរងទុក្ខ (គម្ពីរលោកុប្បត្តិ ៣:១៧-១៨) ។ ជីវិតសត្វបានបង្ហាញលក្ខណៈកាចសាហាវ។ គម្ពីរអេសាយ ១១:៦-៩ បង្ហាញថានៅក្នុងព្រះរាជដែលកំពុងយាងមកដល់របស់ព្រះជាម្ចាស់ សត្វព្រៃទាំងអស់នឹងបានពេញដោយសន្តិភាព មិនមែនកាចសាហាវនោះទេ។ ការនេះនាំឲ្យយើងជឿថារបៀបរបបនៅក្នុងព្រៃបច្ចុប្បន្ននេះគឺជាលទ្ធផលដែលបានមកពីបណ្ដាសារនៃអំពើបាប សត្វខ្លាំងប្រមាញ់សត្វទន់ខ្សោយ ហើយភាពចុះសម្រុងគ្នានៅក្នុងធម្មជាតិក៏ត្រូវបានបង្ខូចអស់។

ជីវិតរុក្ខជាតិក៏បង្ហាញពីឥទ្ធិពលនៃអំពើបាបផងដែរ។ ស្រងែ និង បន្លាបានរឹតត្បាតរុក្ខជាតិល្អ។ អាហារមិនលូតលាស់ ដោយគ្មានការខិតខំប្រឹងប្រែពីពីសំណាក់យើងឡើយ។ ការប្រឹងប្រែងរបស់យើងដើម្បីអាចទទួលបានអាហារ ពីបរិស្ថានជុំវិញខ្លួន បានធ្វើឲ្យខូចបង់លើរូបកាយរបស់យើងយ៉ាងខ្លាំង។ លោកសាវ័កប៉ុលរៀបរាប់អំពីការនេះ តាមរបៀបដូចនេះ៖

អ្វីៗសព្វសារពើដែលព្រះអង្គបង្កើតមក កំពុងតែអន្ទះអន្ទែង ទន្ទឹងរង់ចាំពេលដែលព្រះជាម្ចាស់នឹងបង្ហាញបុត្ររបស់ព្រះអង្គ ដ្បិតអ្វីៗទាំងអស់នោះបែរទៅជាឥតន័យ តែមិនមែនដោយចិត្តឯងទេ គឺព្រះជាម្ចាស់បានតំរូវដូច្នេះ។ ពិភពលោកនៅតែមានសង្ឃឹមថា ព្រះអង្គនឹងលោះអោយរួចផុតពីវិនាសអន្តរាយ ដើម្បីអោយមានសេរីភាព និងសិរីរុងរឿងនៃបុត្ររបស់ព្រះជាម្ចាស់។ យើងដឹងហើយថា មកទល់ថ្ងៃនេះ ពិភពលោកទាំងមូលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ដូចជាស្ត្រីដែលហៀបនឹងសំរាលកូន។ (គម្ពីររ៉ូម ៨:១៩-២២)

## ការដាច់ចេញ និង ការដាក់ទោសអស់កល្បជានិច្ច

លទ្ធផលចុងក្រោយនៃអំពើបាបដែលយើងនឹងនិយាយនៅពេលនេះគឺជាលទ្ធផលមួយដែលគួរឲ្យក្រៀមក្រំបំផុត។ ព្រះគម្ពីរបង្ហាញថា មនុស្សបាបដែលមិនលន់តួទេនោះ នឹងត្រូវរងការដាក់ទោសអស់កល្បជានិច្ច។ ខ្ញុំពិតជាចង់ឲ្យមានលទ្ធផលខុសពីនេះណាស់ ប៉ុន្តែខ្ញុំក៏មិនហ៊ានបិទភ្នែករបស់ខ្ញុំធ្វើជាមើលមិនឃើញពាក្យដ៏ច្បាស់លាស់ទាំងអស់នោះដែរ។

## *លំហាត់អនុវត្តន៍*

១២ ចូរបើកព្រះគម្ពីររកមើលបទគម្ពីរទាំងនេះ ហើយ និយាយអំពីអ្វីដែលបទគម្ពីរបានបង្ហាញអំពីការដាក់ទោសដ៏អស់កល្បជានិច្ច។

ក) គម្ពីរម៉ាថាយ ២៥:៤១

ខ) គម្ពីរម៉ាកុស ៩:៤៨

គ) គម្ពីររ៉ូម ២:៨-៩

ឃ) គម្ពីរយ៉ូដាស ១៣

ង) គម្ពីរវិវរណៈ ១៤:១០-១១

---

ស្របពេលដែលយើងឃើញថា ពេលខ្លះអ្នកសរសេរព្រះគម្ពីរ បាននិយាយសំដៅទៅកាន់ការដាក់ទោសនេះថាជា*ការបំផ្លិចបំផ្លាញ* ការដាក់ទោសនេះនឹងស្ថិតនៅជាប់ជារៀងដរាប (មើលគម្ពីរទំនុកតម្កើង ៥២:៥ គម្ពីរ២ថេស្សាឡូនិក ១:៦-៩)។ ចូរសំគាល់មើលនៅក្នុងគម្ពីរម៉ាថាយ ២៥:៤៦ ថា ពាក្យអស់កល្បជានិច្ចគឺត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់ទាំងស្ថានសួគ៌ និង ស្ថាននរកៈ ការដាក់ទោសដ៏អស់កល្បនិច្ច (ឋាននរក) ជីវិតអស់កល្ប (ឋានសួគ៌) ។ លុះត្រាតែមនុស្សប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយដោះស្រាយបញ្ហាអំពើបាបរបស់ពួកគេ បើពុំនោះទេពួកគេនឹងទទួលរងនូវការដាក់ទណ្ឌកម្មអស់កល្បជានិច្ចដាច់ចេញពីវត្តមានរបស់ព្រះអម្ចាស់។ ។

# ខ. ការស្រោចស្រង់មនុស្សមានបាប

**វត្ថុបំណងទី៥.** *បកស្រាយពីរបៀបដែលមនុស្សមានបាប ត្រូវបានស្រោចស្រង់ និង បកស្រាយពីលទ្ធផលនៃការស្រោចស្រង់។*

នៅកណ្តាលចំណោមភាពអស់សង្ឃឹម ពន្លឺនៃក្តីសង្ឃឹមមួយនឹងចែងចាំងឡើង។ ព្រះជាម្ចាស់ជាមួយសេចក្តីមេត្តាករុណារបស់ទ្រង់ បានប្រទានមធ្យោបាយឲ្យគេចផុតពីផលវិបាកនៃការស្លាប់ខាងឯវិញ្ញាណ។ ទ្រង់បានប្រទានរបៀបដែលអាចទទួលបានសិរីរុងរឿងអស់កល្បជានិច្ច នៅក្នុងព្រះវត្តមានរបស់ទ្រង់ សម្រាប់អស់អ្នកដែលនឹងទទួលយក ការប្រទានប្រកបដោយសេចក្តីមេត្តារបស់ទ្រង់។ អ្នក និង ខ្ញុំ អាចទទួលបានការស្រោចស្រង់ទាំងខាងឯវិញ្ញាណ និង ខាងឯរូបកាយ ហើយឥទ្ធិពលនៃអំពើបាបក៏អាចនឹងរំសាយចេញ។

## ការស្រោចស្រង់ខាងឯវិញ្ញាណ

ព្រះជាម្ចាស់បានប្រទានការស្រោចស្រង់ខាងឯវិញ្ញាណរបស់យើង តាមរយៈការសុគតរបស់ព្រះបុត្រទ្រង់គឺព្រះយេស៊ូ ដែលបានធ្វើជាអ្នកជំនួសកន្លែងយើង ដើម្បីធ្វើការបង់ថ្លៃជួសបាបរបស់យើង។ ការនេះមានបកស្រាយនៅក្នុងគម្ពីរយ៉ូហាន ៣:១៦-១៧ ៖

> ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ។ ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គ អោយយាងមកក្នុងលោកនេះ ពុំមែនដើម្បីដាក់ទោសមនុស្សលោកទេ គឺដើម្បីសង្គ្រោះមនុស្សលោក ដោយសារព្រះបុត្រាវិញ។

អ្នក និង ខ្ញុំ មានឱកាសទទួលបានការស្រោចស្រង់ខាងឯវិញ្ញាណ ប្រសិនបើយើងលន់តួបាបរបស់យើង និង ធ្វើការសម្រេចចិត្ត ចាកចេញពីគ្រប់អំពើបាបរបស់យើង។ ទោះជាយ៉ាងណា យើងត្រូវទទួលការប្រទានសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ ហើយទទួលយកសេចក្តីសន្យារបស់ទ្រង់ដើម្បីជួយយើងរាល់គ្នា។ ការនេះទាមទារឲ្យមានសកម្មភាពនៃជំនឿមួយ ដូចព្រះគម្ពីរបានថ្លែងថា៖ "ព្រះអង្គសង្គ្រោះបងប្អូនដោយសារព្រះគុណ តាមរយៈជំនឿ" (គម្ពីរអេភេសូ ២:៨) ។ តម្រូវការចុងក្រោយមួយនោះគឺថា យើងប្រកាសថា "ព្រះយេស៊ូពិតជាព្រះអម្ចាស់" (គម្ពីររ៉ូម ១០:៩) ។ នៅពេលដែលយើងជឿលើទ្រង់សារភាព និង លះបង់អំពើបាបរបស់យើង ហើយអនុញ្ញាតឲ្យព្រះយេស៊ូគង់ធ្វើជាព្រះអម្ចាស់ក្នុងជីវិតរបស់យើង នោះយើងនឹងត្រូវបានផ្លាស់ប្តូរ។ យើងទទួលបានជីវិតខាងឯវិញ្ញាណ (គម្ពីរអេភេសូ ២:១-៩ គម្ពីរកូឡុស ២:១៣) ហើយយើងក៏បានក្លាយទៅជាមនុស្សថ្មីនៅក្នុងព្រះគ្រិស្ត៖ "ប្រសិនបើអ្នកណាម្នាក់នៅរួមជាមួយព្រះគ្រិស្ត អ្នកនោះបានកើតជាថ្មី អ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានប្រែមកជាថ្មីវិញ" (គម្ពីរ២កូរិនថូស ៥:១៧) ។ លោកសាវ័កប៉ូល ដាស់តឿនអ្នកជឿឲ្យលះបង់និស្ស័យចាស់ចេញ ហើយដើរតាមព្រះជាម្ចាស់បង្កើតយើងសាជាថ្មីម្តងទៀត នៅក្នុងខ្លួនប្រាណថ្មីមួយដែលនឹងថ្វាយសិរីរុងរឿងទៅដល់ទ្រង់ (គម្ពីរអេភេសូ ៤:១៧-២៨ គម្ពីរកូឡុស ៣:១-១៧)

តាមរយៈការសុគតរបស់ទ្រង់ ព្រះអម្ចាស់នៃយើងបានបង់ថ្លៃទោសបាបរបស់យើង ព្រមទាំងបានរំងាប់ព្រះពិរោធដ៏ត្រឹមត្រូវរបស់ព្រះជាម្ចាស់ទាស់នឹងអំពើបាបនោះផងដែរ។ យើងបានក្លាយជាមនុស្សសុចរិត តាមរយៈទ្រង់។ ទ្រង់ធានាបាននូវការអត់ទោសសម្រាប់យើង ហើយប្រទានមកនូវការប្រោសលោះដ៏ពេញលេញ និង ឥតគិតថ្លៃ។ ទ្រង់ក៏ប្រទានិស្ស័យថ្មីសម្រាប់យើងផងដែរ។ ទោះបីជាយើងបានកើតមកជាមួយនឹងនិស្ស័យដ៏សៅហ្មងយ៉ាងនេះក្ដី ទ្រង់បានទទួលយកយើងឲ្យចូលទៅក្នុងគ្រួសារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ លើសពីនេះទៅទៀត ទ្រង់ប្រទានឲ្យយើងនូវឋានៈជាបុត្ររបស់ព្រះជាម្ចាស់ ហើយបានធ្វើឲ្យយើងក្លាយជាអ្នកស្នងមរតករបស់ព្រះជាម្ចាស់ផងដែរ (គម្ពីររ៉ូម ៨:១៧)។ ព្រះអម្ចាស់នៃយើងមិនត្រឹមតែបានធ្វើការរៀបចំទាំងនេះសម្រាប់ការស្រោចស្រង់វិញ្ញាណរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ដើរតួជាមេធាវីរបស់យើង ជាអ្នកសម្រុះសម្រួលដែលចាំជួយអង្វរ ទៅកាន់តុលាការដ៏ពេញដោយព្រះចេស្ដា ហើយទូលសូមឲ្យទ្រង់មានព្រះហឫទ័យមេត្តាមកលើយើងរាល់គ្នាផងដែរ (គម្ពីរហេប្រឺ ៧:២៥ គម្ពីរ ១យ៉ូហាន ២:១)។

រួមជាមួយនឹងព្រះអំណោយទាននៃការសង្គ្រោះ មានទំនួលខុសត្រូវផ្សេងទៀតសម្រាប់អ្នកជឿថ្មី។ ពួកគេត្រូវ "ដើរនៅក្នុងពន្លឺ" (គម្ពីរ១យ៉ូហាន ១:៧ គម្ពីរយ៉ូហាន ១:៤-៩)។ ស្របពេលដែលគ្រិស្តបរិស័ទនឹងមិនអាចឈានទៅដល់ភាពល្អឥតខ្ចោះនៅក្នុងជីវិតនេះទេ ពួកគេអាចដើរនៅក្នុង*ពន្លឺ* ហើយស្ដាប់បង្គាប់តាមពន្លឺនោះផងដែរ។ ពេលដែលពួកគេធ្វើយ៉ាងដូច្នេះ មានរឿងពីរយ៉ាងនឹងកើតមានឡើង ១) ពួកគេមានសម្ព័ន្ធភាពជាមួយនឹងអ្នកជឿដទៃទៀត និង ២) ពួកគេត្រូវបានជម្រះឲ្យជ្រះស្អាត ។ ការលាងជម្រះកើតមានឡើងនៅពេលដែលអ្នកអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញពីការធ្លាក់ចុះរបស់ពួកគេ កំហុសរបស់ពួកគេ ឬ អំពើបាបគ្រប់យ៉ាងរបស់ពួកគេ។ ពួកគេត្រូវបន្តសារភាពបាបទាំងនេះហើយបន្តគោលបំណងក្នុងការបដិសេធសេចក្ដីល្បួង នៅពេលដែលពួកគេរស់នៅក្នុងក្រោមការគ្រប់គ្រងរបស់ព្រះវិញ្ញាណ (គម្ពីររ៉ូម ៨:៥)។ (សម្រាប់ការសិក្សាឲ្យបានកាន់តែច្បាស់លាស់ថែមទៀត អំពីគោលលទ្ធិនៃសេចក្ដីសង្គ្រោះ សូមមើលនៅក្នុងវគ្គសិក្សារបស់សាកលវិទ្យាល័យគ្លូបល ដែលមានចំណងជើងថា *ជីវិតរស់នៅក្នុងព្រះគ្រិស្ត ៖ ការសិក្សាអំពីសេចក្ដីសង្គ្រោះ)*

## *លំហាត់អនុវត្តន៍*

១៣ ដោយផ្អែកទៅលើការសិក្សាទិដ្ឋភាពមួយនេះ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នក នូវរឿងបីយ៉ាងដែលព្រះយេស៊ូបានធ្វើសម្រាប់យើង តាមរយៈការសុគតនៅលើឈើឆ្កាងរបស់ទ្រង់។

## ការស្រោចស្រង់ខាងរូបកាយ

ព្រះយេស៊ូមិនត្រឹមតែបានប្រទានការស្រោចស្រង់ខាងវិញ្ញាណសម្រាប់យើងប៉ុណ្ណោះទេ ប៉ុន្តែការសុគតរបស់ទ្រង់ នៅលើឆ្កាងក៏បានធ្វើឲ្យមានការស្រោចស្រង់ខាង*រូបកាយ* របស់យើងផងដែរ។ ជំងឺដែលជាទិដ្ឋភាពមួយនៃបណ្ដាសារ ក៏មិនអាចតោងជាប់មនុស្សជាតិបានទៀតដែរ នៅពេលដែលព្រះគ្រិស្តបានរងទុក្ខនៅលើឈើឆ្កាង។ ព្រះគម្ពីរបានបង្រៀនអំពី ការប្រោសឲ្យជា គឺជាទិដ្ឋភាពមួយនៃការស្រោច

ស្រង់ដែលទ្រង់បានសម្រេចបាន។ មានកំណាព្យដ៏ពិរោះរណ្តំខ្លះនៅក្នុងព្រះគម្ពីរ បានសរសេរសំដៅទៅលើការប្រោសជំងឺដែលព្រះទ្រង់បានប្រទាន៖

តាមពិតលោកបានរងទុក្ខវេទនាជំនួសយើង
លោកទទួលយកការឈឺចាប់របស់យើងមកដាក់លើខ្លួនលោក។

រីឯយើងវិញ យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក
ព្រះអង្គបានវាយ និងបន្ទាបបន្ថោកលោក។

ប៉ុន្តែ លោកត្រូវគេចាក់ទម្លុះព្រោះតែការបះបោររបស់យើង
លោកត្រូវគេជាន់ឈ្លី ព្រោះតែអំពើទុច្ចរិតរបស់យើង

លោកបានរងទារុណកម្មដើម្បីអោយយើងទទួលសេចក្តីសុខសាន្ត
ហើយដោយសារស្នាមរបួសរបស់លោកយើងក៏បានជាសះស្បើយ។
—គម្ពីរអេសាយ ៥៣:៤-៥

## *លំហាត់អនុវត្តន៍*

១៤ ចូរបើកទៅមើលខគម្ពីរខាងក្រោម ហើយប្រាប់អំពីអ្វីដែលបទគម្ពីរនីមួយៗថ្លែងអំពីការប្រោសឲ្យជាដែលមកពីព្រះជាម្ចាស់។

ក) គម្ពីរម៉ាថាយ ៨:១៧

ខ) គម្ពីរ១ពេត្រុស ២:២៤

ព្រះយេស៊ូបានប្រោសមនុស្សមានជំងឺជាច្រើននាក់ ឲ្យបានជាសះស្បើយ នៅក្នុងគ្រប់ព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់នៅលើផែនដីនេះ។ ទ្រង់ក៏បានណែនាំអស់អ្នកដែលទ្រង់ចាត់បញ្ជូនទៅ ធ្វើព័ន្ធកិច្ច ក្នុងការចែកចាយដំណឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និង ធ្វើការប្រោសអ្នកជំងឺ (សូមមើលគម្ពីរម៉ាថាយ ១០:៧-៨ គម្ពីរម៉ាកុស ១៦:១៨ គម្ពីរលូកា ៩:១-២; ១០:៩)។

បន្ទាប់ពីព្រះយេស៊ូត្រូវបានលើកឡើង ទៅឯស្ថានបរមសុខ ការអស្ចារ្យនៃការប្រោសជំងឺ នៅតែបន្តធ្វើឡើងទៀត តាមរយៈអ្នកដែលដើរតាមទ្រង់។ កណ្ឌគម្ពីរកិច្ចការ មានពេញទៅដោយការអស្ចារ្យនៃការប្រោសជំងឺ។ លើសពីនេះទៅទៀត លោកយ៉ាកុបបង្រៀនថា ចាស់ព្រឹទ្ធាចារ្យនៅក្នុងក្រុមជំនុំគួរតែអធិស្ឋានសម្រាប់អ្នកឈឺ ហើយរំពឹងទុកថាព្រះជាម្ចាស់នឹងប្រោសពួកគេ (គម្ពីរយ៉ាកុប ៥:១៤) ។ ការនេះគឺស្របគ្នាជាមួយនឹង ព្រះបន្ទូលរបស់ព្រះយេស៊ូដែលថា ទ្រង់យាងមកដើម្បីឲ្យយើងអាចមានជីវិត "ពេញបរិបូណ៌" (គម្ពីរយ៉ូហាន១០:១០)។

ពិភពលោកនេះមិនទាន់រួចផុតពីជំងឺ និង ការរងទុក្ខទាំងអស់នោះទេ ប៉ុន្តែទីបន្ទាល់ដែលមាននៅក្នុងគ្រប់ប្រវត្តិសាស្ត្ររបស់ក្រុមជំនុំ គឺថាអស់អ្នកដែលទុកចិត្តលើព្រះយេស៊ូ អាចត្រូវបានប្រោសឲ្យជានៅក្នុងការឆ្លើយតបចំពោះសេចក្ដីអធិស្ឋានដែលពេញដោយជំនឿ។ ដូច្នេះ យើងអាចទទួលបាននូវគុណប្រយោជន៍ខាងឯវិញ្ញាណ រូបកាយ និង ភាពអស់កល្បជានិច្ច ដោយព្រោះមានការប្រទានមកពីព្រះអម្ចាស់នៃយើង ដែលបានធ្វើនៅលើឈើឆ្កាងលើភ្នំកាល់វ៉ារី(គាល់កូថា,លលាដ៏ក្បាល)។ តាមរយៈលោកអដាំ អំពើបាបបានចូលមកក្នុងអម្បូររបស់មនុស្ស តែតាមរយៈព្រះយេស៊ូគ្រិស្ត យើងត្រូវបានរំដោះឲ្យមានសេរីភាពផុតពីបាប និង ឥទ្ធិពលរបស់អំពើបាប! សូមឲ្យយើងបើកដួងចិត្តរបស់យើង ដោយលើកតម្កើងទ្រង់ ដោយព្រោះព្រះអំណោយទាននៃការសង្គ្រោះដ៏អស្ចារ្យរបស់ទ្រង់!

## លំហាត់អនុវត្តន៍

១៥ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវដែលទាក់ទងនឹងការស្រោចស្រង់រូបកាយ និង វិញ្ញាណរបស់យើង។

ក) ទិដ្ឋភាពមួយដ៏សំខាន់ជាងគេបំផុតនៃការស្រោចស្រង់វិញ្ញាណ គឺថា ការនោះបាននាំយើងត្រឡប់ទៅរកទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ឡើងវិញ។

ខ) ដោយសារតែព្រះយេស៊ូបានសុគតនៅលើឈើឆ្កាង ក្នុងនាមជាអ្នកជំនួសបាបយើង ឥឡូវមនុស្សទាំងអស់គ្នា បានមានសេរីភាពផុតការផ្ដន្ទាទោសនៃអំពើបាប។

គ) ការស្រោចស្រង់ខាងឯវិញ្ញាណទាមទារឲ្យមានការលន់តួ ងាកចេញពីបាប និង ការដើរនៅក្នុងពន្លឺ។

ឃ) ជំងឺគឺជាទិដ្ឋភាពមួយនៃបណ្ដាសារ ដែលយើងរាល់គ្នាត្រូវតែទទួលស្គាល់ថាជាទិដ្ឋភាពមួយនៃជីវិត។

ង) ការប្រោសជំងឺពីព្រះជាម្ចាស់ គឺទាមទារឲ្យមានជំនឿ។

ច) ការដើរនៅក្នុងពន្លឺ នាំឲ្យមានការសម្អាតឲ្យផុតពីបាប និង មានការប្រកបទាក់ទងអ្នកជឿដទៃទៀត។

ឆ) មនុស្សជាច្រើនរាប់មិនអស់ តាំងពីជំនាន់សម្ព័ន្ធមេត្រីថ្មីមកដល់បច្ចុប្បន្ននេះ ធ្លាប់បានឆ្លងកាត់ការប្រោសជំងឺមកពីព្រះជាម្ចាស់ ។

ជ) រឿងដ៏ចាំបាច់តែមួយគត់ ដើម្បីទទួលការប្រោសមកពីព្រះជាម្ចាស់ គឺការអធិស្ឋានរបស់ពួកចាស់ព្រឹទ្ធាចារ្យនៅក្នុងក្រុមជំនុំ។

ឈ) ផលវិបាកទាំងអស់ ដែលលោកអដាំបានទំលាក់មកលើអម្បូរមនុស្ស ត្រូវបានយកឈ្នះលើដោយការសុគតជួស របស់ព្រះយេស៊ូនៅលើឈើឆ្កាង។

# *ការប្រឡងផ្ទាល់ខ្លួន*

**ចម្លើយខ្លីៗ** ៗ ចូរបំពេញប្រយោគខាងក្រោម។

១ ដើមកំណើតនៃអំពើបាបនៅក្នុងអម្បូររបស់មនុស្ស អាចត្រូវគេឃើញមានពីអំពើបាបរបស់ ......................................................................................................................................។

២ ដើមកំណើតនៃអំពើបាបនៅក្នុងសាកលលោកអាច ត្រូវបានគេឃើញមានតាំងពីការបះបោររបស់ ......................................................................................................................................។

៣ ភស្តុតាងពីរយ៉ាងនៃធាតុពិតរបស់អំពើបាប គឺ .................................................................។

៤ មធ្យោបាយចាំបាច់ក្នុងការស្រោចស្រង់មនុស្សមានបាបគឺ.....................................................។

៥ ផលវិបាកដែលគួរឲ្យក្រៀមក្រំ និង ធ្ងន់ធ្ងរជាងគេនៃអំពើបាបគឺ.............................................។

**ត្រូវ/ខុស**ៗ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ខាងមុខប្រយោគ ប្រសិនបើប្រយោគនោះត្រឹមត្រូវ ។ ចូរសរសេរ ខ ប្រសិនប្រយោគនោះមិនត្រឹមត្រូវ។

.........៦ ប្រសិនបើសាតាំងមិនបានប្រព្រឹត្តិបាបមុនដំបូងគេនោះទេ មនុស្សនឹងមិនអាចប្រព្រឹត្តិអំពើបាបបាននោះទេ។

........៧ ក្រឹត្យវិន័យគឺចាំបាច់ណាស់ ព្រោះមនុស្សសុទ្ធតែមាននិស្ស័យបាប។

........៨ ព្រះគម្ពីរបានផ្តល់នូវភស្តុតាងជាច្រើន អំពីការដែលមនុស្សមិនអាចផ្គាប់ព្រះទ័យព្រះជាម្ចាស់បានដោយខ្លួនឯង។

........៩ យោងទៅតាមភស្តុតាងនៅក្នុងព្រះគម្ពីរ អំណួត និង ភាពអាត្មានិយម នាំឲ្យមានការធ្លាក់ចុះរបស់សាតាំង។

........១០ យុទ្ធសាស្ត្ររបស់សាតាំនៅក្នុងពិភពលោកសព្វថ្ងៃនេះ គឺមានគម្រោងដែលខុសពីគម្រោងរបស់ព្រះជាម្ចាស់ទាំងស្រុង។

.......១១ ការបរិភោគផ្លែឈើដែលនាងអេវ៉ាបានធ្វើនោះ គឺជាអំពើបាបលុះត្រាតែផ្លែឈើនោះត្រូវបានព្រះជាម្ចាស់ហាមមិនឲ្យបរិភោគ។

.......១២ ដោយអំពើបាបបានចូលមកក្នុងពូជអម្បូររបស់មនុស្ស យើងក៏បានកើតមកជាមួយនឹងនិស្ស័យខាងវិញ្ញាណដែលបានស្លាប់បាត់ទៅហើយ។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៨ ចម្លើយរបស់អ្នកគួរតែបូករួមគំនិតទាំងនេះ៖ ព្រះជាម្ចាស់បានសម្រេចព្រះទ័យប្រទានឲ្យមនុស្សជាតិនូវសមត្ថភាព ក្នុងការជ្រើសរើសបម្រើព្រះជាម្ចាស់ដោយខ្លួនឯង។ ការនេះទាមទារឲ្យមានការសាកល្បងមួយ ដែលមានការធ្វើការជ្រើសរើសមួយ។ លោកអដាំ និង នាងអេវ៉ា ដែលជាឪពុកម្ដាយដំបូងបង្អស់របស់មនុស្សរាល់គ្នា បានជ្រើសរើសដើរតាមបំណងចិត្តអាត្មានិយមរបស់ពួកគាត់ ដោយមិនជ្រើសការផ្ចង់ចិត្តទៅរកព្រះជាម្ចាស់ឡើយ។ ដោយសារតែពួកគាត់បានប្រព្រឹត្តិអំពើបាបទាស់នឹងព្រះជាម្ចាស់ ដោយការមិនស្ដាប់បង្គាប់តាមក្រឹត្យវិន័យរបស់ទ្រង់ យើងក៏បានទទួលស្នងនិស្ស័យដែលពេញដោយបាបរបស់ពួកគាត់។ ការដាក់ទោសរបស់ព្រះជាម្ចាស់ គឺយុត្តិធម៌ណាស់ ព្រោះលោកអដាំ និង នាងអេវ៉ា ធ្វើការសម្រេចចិត្តដោយខ្លួនឯង ក្នុងការជ្រើសរើសរវាងព្រះជាម្ចាស់ និង អំពើអាក្រក់ ដោយដឹងស្រាប់ថា ពួកគាត់នឹងអាចទទួលផលវិបាកយ៉ាងជាក់ច្បាស់។

១ មិនស្ដាប់បង្គាប់ព្រះជាម្ចាស់

៩ ក) ៣) ភាពអាត្មានិយម
ខ) ៥) ការប្រទ្បាក់
គ) ២) ខុសគោលដៅ
ឃ) ១) អំពើរំលង
ង) ៤) ការបះបោរ

២ មនុស្សជំនាន់ក្រោយប្រព្រឹត្តអំពើអាក្រក់ ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់ (ពួកគេប្រព្រឹត្តិបាបទាស់នឹងព្រះជាម្ចាស់)។

១០ ក) ៤) មនសិការ
ខ) ១) សតិបញ្ញា
គ) ៥) វិញ្ញាណ (បានស្លាប់ទៅហើយ)
ឃ) ២) វេទនារម្មណ៍ និង អារម្មណ៍
ង) ៣) ឆន្ទៈ

៣ ប្រជាជនអ៊ីស្រាអែលបានប្រព្រឹត្តិអំពើអាក្រក់ ដែលមិនគាប់នឹងព្រះទ័យព្រះជាម្ចាស់ ម្ដងហើយម្ដងទៀត។

១១ ក) យើងរងទុក្ខសព្វថ្ងៃនេះ មិនមែនគ្រាន់តែ ដោយសារអំពើបាបរបស់លោកអដាំ និង និស្ស័យបាបដែលយើងបានស្នងនោះទេ ប៉ុន្តែក៏ជាផលវិបាកដែលបានមកពីអំពើបាបរបស់អ្នកដទៃផ្សេងទៀតផងដែរ។

៤ អំពើបាបគឺជាការមិនស្ដាប់បង្គាប់ និង ការបរាជ័យក្នុងការប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ វាគឺជា អ្វីៗគ្រប់យ៉ាងដែលមនុស្សធ្វើខុស។

១២ ក) អស់អ្នកដែលត្រូវបណ្តាសារ នឹងត្រូវធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ចរួមជាមួយ មារសាតាំង និង ទេវតា(បរិវារ)របស់វា។

ខ) អស់អ្នកដែលត្រូវទទួលទោស នឹងត្រូវបានបោះចូលទៅក្នុងនរក ដែលជាកន្លែងមានដង្កូវមិន ចេះងាប់ និង ភ្លើងមិនចេះរលត់។

គ) សម្រាប់អស់អ្នកដែលប្រព្រឹត្តិអំពើអាក្រក់ នឹងមាន ព្រះពិរោធ និងដាក់ទោសយ៉ាងធ្ងន់ ទុក្ខ លំបាក ការតប់ប្រមល់ អន្ទះអន្ទែង។

ឃ) ការដាក់ទោសដ៏អស់កល្បជានិច្ច ក៏មានរួមបញ្ចូល ទីងងឹតសូន្យសុងដែរ។

ង) អស់អ្នកដែលបដិសេធព្រះជាម្ចាស់ នឹងត្រូវរងទុក្ខទោសនៅក្នុងភ្លើង និងក្នុងស្ពាន់ធ័រ ពួកគេ នឹងត្រូវវេទនា ទាំងថ្ងៃទាំងយប់ ឥតស្រាកស្រាន្តឡើយ។

៥ ចម្លើយរបស់អ្នកអាចនឹងមានគំនិតទាំងនេះដែរ៖ ព្រះគម្ពីរបានផ្តល់នូវភស្តុតាងប្រវត្តិសាស្ត្រអំពី ធាតុពិតនៃអំពើបាប ចាប់ផ្តើមពីអំពើបាបរបស់លោកអដាំ និង នាងអេវ៉ា លោកកាអ៊ីន ហើយបន្ទាប់ មកទៀត មានអំពើបាបរបស់ជនជាតិអ៊ីស្រាអែលដែលកើតឡើងម្តងហើយម្តងទៀត។ នៅក្នុងគម្ពីរ សម្ព័ន្ធមេត្រីថ្មី គឺជាការកត់ត្រាអំពីការផ្គត់ផ្គងរបស់ព្រះជាម្ចាស់ សម្រាប់បញ្ហាអំពើបាប តាមរយៈព្រះ យេស៊ូគ្រិស្ត ហើយក៏បានផ្តល់នូវឧទាហរណ៍ជាច្រើនអំពីអំពើបាប។ នៅគ្រប់ទីកន្លែងលើពិភព លោកនេះ សុទ្ធតែត្រូវការគ្រប់គ្រងដឹកនាំ ព្រោះមនុស្សដែលបានបណ្តោយឲ្យនូវតែម្នាក់ឯង មាន ភាពអាត្មានិយម និង ចង់តែបះបោរ។

១៣ ចម្លើយនៅក្នុងចំណោមចម្លើយខាងក្រោមនេះ ។ ទ្រង់បានរំសាយព្រះពិរោធរបស់ព្រះជាម្ចាស់ដែល មានចំពោះអំពើបាប ។ ទ្រង់បានបង់ថ្លៃជួសបំណុលបាបរបស់យើង ដោយបានធានាការអត់ទោស និង ប្រទានការប្រោសលោះដែលពេញបរិបូរណ៌ និង មិនឥតគិតថ្លៃ ។ ទ្រង់ប្រទាននិស្ស័យថ្មីមួយ មកឲ្យយើង ហើយធ្វើឲ្យយើងក្លាយទៅជាបុត្រ និង ជាអ្នកស្នងសម្បត្តិរបស់ព្រះជាម្ចាស់។ ទ្រង់បាន ទូលអង្វរជំនួសយើងនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ហើយទ្រង់ប្រទានពន្លឺសម្រាប់ការធ្វើ ដំណើរប្រចាំថ្ងៃរបស់យើង។

៦ ចម្លើយគ) ឃ) និង ង) ជាចម្លើយត្រឹមត្រូវ។

១៤ ក) ទ្រង់បានទទួលភាពពិការ និង ជំងឺរបស់យើង។

ខ) ដោយសារតែស្នាមរបួសរបស់ទ្រង់ យើងបានជាសះស្បើយ។

៧ ក) លោកត្រូវបានកាត់ទោស ឲ្យស្លាប់។

ខ) សេចក្តីស្លាប់។

១៥ ចម្លើយក) គ) ង) ច) ឆ) និង ឈ) គឺជាចម្លើយត្រឹមត្រូវ។

## ការប្រឡងក្នុងជំពូកទីពីរ

ឥឡូវនេះ ដោយអ្នកបានបញ្ចប់ជំពូកទីពីរ អ្នកអាចឆ្លើយនឹងសំណួរវាយតម្លៃជំពូកទីពីរបាន។ ចូររំឭកមេរៀនពីខាងលើ មុនពេលដែលអ្នកចាប់ផ្ដើម។ ធ្វើតាមការណែនាំដ៏ប្រុងប្រយ័ត្ន ដើម្បីធ្វើការប្រឡងបន្ទាប់មក បន្តទៅជំពូកទីបី